ភ្នែកគាត់ ។ លុះទៅដល់កន្លែងនោះភ្លាម, គាត់ក៏ពោលថា: “គឺកន្លែងនេះហើយដែលគេបានរុំមុខខ្ញុំ ហើយគេបង្វិលខ្លួនខ្ញុំដូចខ្ញុំធ្វើឱ្យមើលនេះ ។ កូនចោរដែលមានកូនកន្សែងកាន់ប្រុងនៅដៃស្រាប់ ក៏រុំភ្នែកលោកតាយើង, ហើយវាក៏នៅជិតនោះ, ជួនកាលវាដឹកដៃគាត់, ជួនកាលវាលែងឱ្យគាត់ទៅតាមចិត្ត, លុះត្រាតែទៅដល់កន្លែងមួយលោកតាយើងឈប់ឈរទ្រឹង” ។

មុស្តាហ្វាក៏ពោលថា : “តាមខ្ញុំប្រមាណក្នុងចិត្តទៅថា ខ្ញុំដើរទៅមិនជាឆ្ងាយប៉ុន្មានទេ” កន្លែងដែលតាយើងឈប់នោះ គឺនៅចំមុខផ្ទះកាស៊ីម ដែលអាលីបាបា កំពុងនៅក្នុងនោះ ។ មុននឹងស្រាយកន្សែងចេញពីភ្នែកជរាជន, អាចោរក៏បានយកដីសគូសក្លោងទ្វារផ្ទះនោះជាសញ្ញា ។ លុះវាស្រាយកន្សែងចេញពីភ្នែកតាយើង, វាក៏សួរតាយើងថា តើតាដឹងទេ ផ្ទះនេះជាផ្ទះនរណា ។ មុស្តាហ្វាក៏ឆ្លើយថា គាត់ពុំដែលមកសង្កាត់នេះទេ, ដូច្នេះគាត់ក៏ពុំបានប្រាប់អាចោរថាដូចម្ដេចឡើយ ។

អាចោរ កាលបើវាសម្លឹងឃើញថា វាពុំអាចយកការណ៍អ្វីពីមុស្តាហ្វាបានទៀត, វាក៏និយាយអរគុណគាត់ចំពោះការនឿយហត់របស់គាត់ ។ ក្រោយពីតាយើងត្រឡប់ទៅហាងគាត់វិញ, ចោរនោះក៏ដើរតាមផ្លូវតម្រង់ទៅព្រៃវិញ, ជឿជាក់ក្នុងចិត្តថាខ្លួនស៊ើបការណ៍បានច្បាស់ហើយ ។



ក្រោយពីអាចោរនិងបាបា-មុស្តាហ្វាលាគ្នាចេញបន្តិចទៅ, នាងមរ្ស៊ីយ៉ានពុំដឹងជាមានការអ្វីក៏ចេញពីផ្ទះដែរ ។ លុះត្រឡប់មកវិញ នាងសម្គាល់ឃើញសញ្ញាដែលអាចោរបានធ្វើ, នាងក៏ឈប់ពិនិត្យមើលហើយនឹកក្នុងចិត្តថា : “តើសញ្ញានេះមានន័យដូចម្ដេច? ជនណាម្នាក់ចង់បៀតបៀនចៅហ្វាយខ្ញុំឬៗ ក៏គេធ្វើលេងសប្បាយទេ ? នាងគិតថា ទោះបីគេមានបំណងយ៉ាងណាក៏ដោយ, យើងត្រូវតែប្រុងប្រយ័ត្នខ្លួននឹងព្រឹត្តិការណ៍នេះ” ។ គិតដូច្នោះហើយ, នាងក៏យកដីសមកកាន់ ហើយគូសជាសញ្ញាត្រង់កន្លែងតែមួយនៅគ្រប់ទ្វារទាំងអស់, ព្រោះទ្វារពីរបីទាំងខាងលើទាំងខាងក្រោមមានសភាពដូចគ្នា ។ រួចនាងក៏ដើរចូលទៅក្នុងផ្ទះទៅ, ដោយឥតនិយាយអំពីការដែលនាងទើបនឹងធ្វើនោះប្រាប់ចៅហ្វាយប្រុស ឬចៅហ្វាយស្រីនាងឡើយ ។

ពោលពីអាចោរវិញ, វាបានដើរកាត់ព្រៃទៅដល់ក្រុមវានៅពេលពីព្រលឹម ។ វាបាននិយាយរាយការណ៍ពីលទ្ធផលនៃដំណើរវា, ដោយពោលបញ្ចេញបញ្ចូលអំពីវាសនាល្អ វាបានទៅជួបជនម្នាក់ជាលើកដំបូងបង្អស់ ។ ដោយសារជននោះវាក៏បានដឹងសេចក្ដីសព្វគ្រប់ដែលវានាំយកមកជម្រាបនេះ ។ គ្មានជនណាម្នាក់ក្រៅពីវា ដែលអាចសួរការណ៍នេះពីគាត់ដឹងឡើយ ពួកចោរទាំងឡាយក៏ប្រឹងស្ដាប់យ៉ាងរីករាយ ទើបមេចោរពោលទៅកាន់កូនចោរទាំងឡាយថា : “ភឿនទាំងឡាយ យើងកុំបង្អង់ឱ្យយូរពេលឱ្យសោះ ចូរយើងចេញទៅដោយ

លាក់គ្រឿងសាស្ត្រាវុធឱ្យស្រួល, កុំឱ្យគេស្គាល់យើងថាជានរណាឡើយ" ។ លុះយើងចូលទៅដល់ក្នុងទីក្រុង យើងត្រូវបែកគ្នាមួយទៅមុខមួយទៅក្រោយ ដើម្បីកុំឱ្យគេមានក្តីសង្ស័យ យើងនឹងជួបគ្នានៅទីវាលធំមួយ មួយពួកនៅម្ខាង មួយពួកនៅម្ខាងទៀត, រង់ចាំខ្ញុំទៅមើលឱ្យស្គាល់ផ្ទះសិន ជាមួយនឹងមិត្តយើងដែលទើបនឹងនាំការមកប្រាប់នេះ ដើម្បីខ្ញុំនឹងរិះរកផ្លូវណាដែលប្រសើរជាងគេនោះ ។ សេចក្តីថ្លែងការណ៍របស់ចោរ ក៏ត្រូវគេទះដៃអបអរសាទរ រួចក៏ដល់ពេលគេត្រូវរៀបដំណើរចេញ ។ វាជិះសេះជាក្បួនពីរ១នាក់ផង, បី១នាក់ផង បរឃ្លាតល្មមពីគ្នា ។ ពួកចោរចូលទៅដល់ទីក្រុង ដោយឥតមានគេសង្ស័យឡើយ ។ មេចោរនឹងកូនចោរម្នាក់ចូលទៅដល់ក្រោយគេ កូនចោរបាននាំមេចោរទៅតាមផ្លូវ ដែលវាបានគូសចំណាំផ្ទះ អាលី-បាបា ។ លុះទៅដល់មុខមាត់ទ្វារមួយ ដែលនាងមរ្ស៊ីយ៉ានបានគូសចំណាំដែរ, វាក៏ពោលប្រាប់មេចោរថា គឺជាផ្ទះនឹងហើយ ។ ប៉ុន្តែកាលបើវាចេះតែបរសេះទៅមុខទៀតឥតឈប់ ដើម្បីចោលជើងកុំឱ្យគេសង្ស័យ, មេ-ចោរក៏សង្កេតឃើញគំនូសនោះ មាននៅតែគ្រប់តែទ្វារ នៅកន្លែងតែមួយ, ទើបសួរទៅអ្នកនាំផ្លូវថា តើផ្ទះនេះឬផ្ទះទីមួយមុន ។ អ្នកនាំផ្លូវក៏ទៅជាស្រឡាំងកាំង ទើបវាឆ្លើយស្បថជូនមេចោរថា វាបានគូសតែលើទ្វារមួយគត់ ។ កូនចោរបន្ថែមថា : "ខ្ញុំពុំដឹងសោះហើយថានរណាក៏អាចគូសសញ្ញាដូចគ្នាអ៊ីម្ល៉េះ បើដូច្នេះខ្ញុំចំណាំពុំបានថា ទ្វារណាដែលខ្ញុំបានគូសនោះទេ" ។



មេចោរយល់ថា សេចក្តីប្រាថ្នារបស់ខ្លួនត្រូវអន្តរាយហើយ, ក៏ត្រឡប់ទៅវិញនិយាយប្រាប់ពួកភឿនថា ដំណើរយើងនេះជាដំណើរអលទ្ធផលទេ ដូច្នេះ មានតែយើងត្រឡប់ទៅទីជម្រកទាំងអស់គ្នាវិញ។ មេចោរក៏បរសេះចេញទៅមុន, កូនចោរទាំងឡាយក៏ជិះទៅតាមជាលំដាប់ដូចកាលពេលមក ។

លុះហ្វូងចោរទៅដល់ក្នុងព្រៃជួបជុំគ្នា, មេចោរក៏ពន្យល់ពីហេតុផល ដែលបណ្តាលឱ្យវាបង្គាប់ឱ្យនាំគ្នាត្រឡប់មកវិញ ។ ក្នុងមួយរំពេចនោះ, គេក៏ប្រកាសកាត់ទោសអាចោរមគ្គុទ្ទេសក៏ប្រហារជីវិតបង់, អាចោរនេះក៏ឆ្លើយកាត់ទោសខ្លួនឯងភ្លាម ហើយវាក៏ឱនកយ៉ាងក្លាហានទៅឱ្យជន ដែលមកឈរពីមុខវានោះកាត់ក្បាលភ្លាម ។

ដើម្បីនឹងរក្សាកិត្តិយសក្រុមចោរ ដោយត្រូវតែសងសឹកនូវអំពើដែលបានធ្វើខុសម្តងហើយនោះ កូនចោរមួយទៀតក៏ធានាខ្លួនឡើងថានឹងទទួលចាត់ការនេះ ឱ្យគ្រាន់បើជាងជនរងគ្រោះមុន ។ គេក៏យល់ព្រមឱ្យវាចេញទៅធ្វើការទាក់ទងជាមួយនឹងបាបា-មុស្តាហ្វាដូចជាអាគ្នាវាលើកមុនទៀត។ បាបា-មុស្តាហ្វាក៏នាំអាចោរខាងក្រោយនេះឱ្យទៅស្គាល់ផ្ទះអាលី-បាបា ដោយគេរុំភ្នែកគាត់ដូចជាលើកមុន។ អាចោរក៏គូសសញ្ញាក្រហមនៅមាត់ទ្វារផ្ទះ អាលី-បាបាត្រង់កន្លែងគៀន ព្រមទាំងសង្ឃឹមថា នេះជាមធ្យោបាយដ៏ជាក់លាក់សម្រាប់សម្គាល់ជាមួយនឹងគំនូសស ។

ប៉ុន្តែក្រោយបន្តិចមក. នាងមរ្ជិយ៉ានក៏ចេញពីផ្ទះទៀត ដូចជាថ្ងៃដំបូង លុះនាងត្រឡប់មកវិញសញ្ញាក្រហមក៏ពុំអាចពួននឹងភ្នែកដ៏មុតរបស់នាងបានឡើយ ។ នាងគិតឃើញដល់ហេតុនេះ ដូចជាពីពេលមុនទៀត ទើបនាងក៏ពុំភ្លេចនឹងយកខ្មៅដៃក្រហមដើរគូសជាសញ្ញានៅគ្រប់ទ្វារជិតខាងហើយ ត្រង់កន្លែងគៀនដូចគ្នានឹងអាចោរបានគូស

អប្រិយជនត្រឡប់ទៅកាន់ក្រុមវាវិញ. និយាយអួតពីមធ្យោបាយរបស់ខ្លួនប្រាប់គេថា ម្តងនេះគ្មានអ្វីដែលអាចឱ្យយើងច្រឡំផ្ទះអាលី-បាបាបានឡើយ ។ មេចោរព្រមទាំងកូនក្រុមទាំងឡាយក៏យល់ថា ការនេះនឹងត្រូវបានសម្រេចហើយ ។ ទាំងអស់គ្នាក៏ចេញដំណើរទៅកាន់ទីក្រុង ដោយរបៀបនឹងការប្រុងប្រយ័ត្នដូចជាលើកមុន គឺមានគ្រឿងប្រហារជីវិតជាប់នឹងខ្លួន ប្រុងតែនឹងវាយប្រហារ ។ មេចោរនឹងកូនចោរម្នាក់ជាមគ្គុទេសក៏ ក៏បរសេះតម្រង់ទៅផ្ទះអាលី-បាបា ប៉ុន្តែវាជួបនឹងឧបសគ្គដដែលដូចកាលពីលើកមុន មេចោរក៏ខឹងច្រឡោតឡើង. ឯអាកូនចោរក៏ទាល់គំនិតធ្វើមុខជូរហួញ ។

ឃើញដូច្នោះហើយ. មេចោរក៏បបួលកូនក្រុមខ្លួនត្រឡប់ទៅជំរុំវិញទៀត ។ ម្តងនេះវាពុំសូវសប្បាយដូចលើកមុនទេ អាកូនចោរដែលជាអ្នកទទួលការមើលងាយពីក្រុមខ្លួនក្នុងរឿងនេះ ក៏ត្រូវទទួលទារុណកម្ម ដោយស្ម័គ្រចិត្តដូចជាអាភៀនវាមុនដែរ ។

មេចោរសម្លឹងឃើញក្រុមរបស់ខ្លួនត្រូវព្រាត់ប្រាស់អ្នកក្លាហាន



ពីរនាក់ហើយ ក៏បារម្ភខ្លាចក្រែងចំនួននេះកាន់តែថយចុះទៅទៀត. បើសិនជាវានៅតែបន្តម្រូវឱ្យកូនចោរវា ទៅស៊ើបសួរឱ្យដឹងកន្លែងពិតប្រាកដនៃទីលំនៅ អាលី-បាបាទៀត ។ ដោយមានជនទាំងពីរជាគំរូមកហើយ. មេចោរក៏យល់ថា ពេលនេះយើងត្រូវការកម្លាំងដៃ. យើងមិនត្រូវការយកក្បាលមនុស្សមកធ្វើជាអ្វីទេ។ ហេតុនេះមេចោរក៏ចេញទៅបំពេញភារកិច្ចនេះដោយខ្លួនឯងតែម្តង ។ វាចូលទៅក្នុងទីក្រុង. ហើយដោយបានមុស្តាហ្វាបំភ្លឺបង្ហាញផ្ទះអាលី-បាបា ដូចកូនចោររបស់វាមុនដែរ. វាក៏បានទៅស្គាល់ផ្ទះនោះ ។ ប៉ុន្តែ វាគ្មានធ្វើសញ្ញាអ្វីនៅនឹងផ្ទះនោះទេ ផ្ទុយទៅវិញ. វាខំសង្កេតសម្លឹងមើលចំណាំក្នុងខួរក្បាល ដោយដើរចុះដើរឡើង ជាច្រើនបកនៅមុខផ្ទះនោះ លុះត្រាតែវាទុកចិត្តខ្លួនវាថាអស់ច្រឡំហើយ ។ កាលបើបានពិនិត្យនិងសាកសួរកិច្ចការអ្វីផ្សេងៗសព្វគ្រប់ហើយ វាក៏ត្រឡប់ចូលទៅកាន់ទីរូងថ្មវិញ ដែលមានកូនក្រុមវាចាំនៅទីនោះ ។ វាក៏និយាយភ្លាមថា : “នែភៀនទាំងឡាយ ! គ្មានអ្វីដែលអាចរាំងរាយើងកុំឱ្យធ្វើការសងសឹក ដើម្បីជួសជុលជំងឺចិត្តយើងនោះទេ ខ្ញុំបានស្គាល់ច្បាស់ហើយ នូវផ្ទះអាជនដែលត្រូវមានទោស ។ ហើយមកតាមផ្លូវ ខ្ញុំបាននឹកឃើញមធ្យោបាយមួយ ដែលអាចធ្វើឱ្យវាស្គាល់ដៃ ព្រមទាំងគ្មាននរណាម្នាក់អាចស្គាល់ទីជម្រកនឹងឃ្លាំងយើងផង នេះជាគោលបំណងរបស់យើងក្នុងរឿងនេះ ។ បើមិនដូច្នោះទេ យើងនឹងជួបការចង្រៃអពមង្គល

ទៀត ។ ដើម្បីនឹងសម្រេចគោលបំណងនេះតទៅនេះជាសេចក្ដីព្រាងរបស់ខ្ញុំ ។ កាលបើខ្ញុំថ្លែងការណ៍នេះរួចប្រាប់ បើមាននរណាចេះកល-ឧបាយប្រសើរជាងនេះទៀត, សូមឡើងឱ្យយោបល់ ។ នៅពេលនោះ, មេចោរក៏និយាយពន្យល់កូនចោរពីគំនិតខ្លួនដែលប្រុងធ្វើ ។ កូនចោរទាំងអស់ក៏យល់ព្រមតាម, មេចោរក៏ចាត់គ្នាខ្លះចូលទៅក្នុងភូមិធំ, ខ្លះចូលទៅក្នុងភូមិតូច រកទិញលាឱ្យបាន១៩ និងឪទឹនធំ៣៨ ធ្វើអំពីស្បែកសម្រាប់ដាក់ប្រេង (ប្រេងខាប់ៗ) ប៉ុន្តែឪទឹនមួយដាក់ប្រេងឱ្យពេញ ឪទឹនឯទៀតទុកទទេ ។

មិនយូរប៉ុន្មាន, ពីរបីថ្ងៃក្រោយមក, ពួកចោរក៏បានរកគ្រឿងប្រដាប់បានសព្វគ្រប់ ។ ដោយឪទឹនមានមាត់ចង្អៀតបន្តិច ដើម្បីតម្រូវតាមគំនិតវាៗក៏វះឱ្យធំបន្តិច ។ លុះបញ្ចូលកូនចោរទៅក្នុងឪទឹនមួយៗហើយ ដោយមានគ្រឿងសាស្ត្រាវុធជាប់នឹងខ្លួនផង មេចោរក៏បិទមាត់ឪទឹនស្បែកជិតទៅវិញជាទំនងដូចដាក់ប្រេងពេញ ទុកតែប្រហោងបន្តិចដើម្បីដកដង្ហើម ។ ហើយដើម្បីបន្លំភ្នែកមនុស្សលោក មេចោរក៏ធ្វើជាយកប្រេងលាបពីក្រៅ ។

កិច្ចការបានប្រព្រឹត្តទៅដូច្នេះ, លុះលាទាំងអស់បានផ្ទុកចោរទាំង៣៧ មិនរាប់មេចោរចូលផងទេ និងឪទឹនប្រេងមួយជាស្រេចហើយ មេចោរក៏ធ្វើដំណើរទៅកាន់ទីក្រុង ជាមួយនឹងលាទាំងនោះ ។ វាបានទៅដល់ទីក្រុង នៅពេលប្រហែលជាមួយម៉ោងក្រោយថ្ងៃលិចដូចវា



បានគិតមែន ។ វានាំកូនចោរឆ្ពោះទៅផ្ទះអាលី-បាបា, គិតទុកក្នុងចិត្តជាស្រេចថា នឹងទៅគោះទ្វារសុំគេសំណាក់មួយយប់ ជាមួយនឹងលាទាំងឡាយ ។ លុះទៅដល់, វាមិនទាំងនឿយហត់នឹងគោះទ្វារផង, អាលី-បាបាអង្គុយយកខ្យល់អាកាសនៅមាត់ទ្វារស្រាប់តាំងពីពេលបាយរួច ។ មេចោរក៏បញ្ឈប់លាទាំងអស់ រួចស្រដីទៅកាន់ អាលី-បាបាថា : “លោកម្ចាស់, ខ្ញុំបាទបាននាំប្រេងដូចលោកឃើញស្រាប់នេះមកពីស្រុកឆ្ងាយណាស់ ដើម្បីយកទៅលក់ឯផ្សារនៅថ្ងៃស្អែក ឥឡូវពេលថ្មើរនេះហើយ ខ្ញុំពុំដឹងទៅសំណាក់ឯណា បើសិនជាលោកពុំយល់ទាស់, សូមលោកមេត្តាអនុគ្រោះឱ្យខ្ញុំបាទសំណាក់នៅនេះមួយយប់ផង ខ្ញុំបាទនឹងដឹងគុណលោកពុំភ្លេចឡើយ” ។

ពិតមែនតែ អាលី-បាបា ធ្លាប់បានឃើញជនដែលនិយាយមកកាន់វានោះនៅក្នុងព្រៃ និងថែមទាំងបានស្គាល់សម្លេងនិយាយទៀតផង, តែតើឱ្យគាត់ស្គាល់ជនដែលស្លៀកពាក់ក្លែងក្លាយជាអ្នកជំនួញប្រេងថា ជាមេនៃចោរ៤០ នាក់នោះម្ដេចបាន? ហេតុនេះហើយបានជា អាលី-បាបា និយាយទៅកាន់ជននោះថា : “អ្នកជាមនុស្សត្រូវបានគេទទួលដោយសោមនស្ស, អញ្ជើញចូលមក” ។ ពេលដូច្នេះរួច អាលី-បាបា ក៏បើកផ្លូវឱ្យមេចោរនាំលាចូលមក ។

នៅពេលដំណាលគ្នានោះ, អាលី-បាបា ក៏ស្រែកហៅទាសាម្នាក់ បង្គាប់មិនត្រឹមតែឱ្យយកលានោះទៅបញ្ចូលក្នុងក្រោលទេ គឺឱ្យ

រកចំបើងនិងស្រូវឱ្យវាស៊ីទៀតផង, កាលបើបានយកអីវ៉ាន់ចេញពីខ្នងវាអស់ហើយ ។ បន្ទាប់មក, វាក៏ក្រោកចូលទៅក្នុងផ្ទះបាយ បង្គាប់នាងមរ្សីយ៉ានឱ្យរៀបចំបាយទឹកឱ្យឆាប់ទទួលភ្ញៀវ ដែលទើបនឹងមកដល់ ហើយនិងរៀបគ្រែនៅក្នុងបន្ទប់ជូនភ្ញៀវសំណាក់ ។

អាលី-បាបាធ្វើកិច្ចបន្ថែមដល់ភ្ញៀវ ដើម្បីនឹងទទួលភ្ញៀវតាមបដិសណ្ឋារកិច្ច ដែលវាអាចធ្វើបាន វាបានទៅទាញដៃភ្ញៀវចូលទៅក្នុងបន្ទប់ ដែលវាទុកសម្រាប់ទទួលភ្ញៀវ, ដោយនិយាយនឹងភ្ញៀវថា : វាមិនព្រមអនុញ្ញាតឱ្យភ្ញៀវណាទទួលទានដំណេកនៅកណ្ដាលទីធ្លាឡើយ ។ កិច្ចនេះវាបានធ្វើឡើងបន្ទាប់ពីវាបានឃើញមេចោរ ដាក់អីវ៉ាន់ពីលើខ្នងលារួច។ បានយកលាបញ្ចូលទៅក្នុងក្រោលហើយ មេ-ចោរក៏ទៅរកកន្លែងសំណាក់កណ្ដាលវាល ។ មេចោរបានប្រកែកសុំទោសយ៉ាងម៉ឺងម៉ាត់ ដោយពោលអាងលេសថា កុំឱ្យលំបាកដល់ម្ចាស់ផ្ទះ ប៉ុន្តែតាមពិត វាចង់បានកន្លែងស្រួល ដើម្បីនឹងបំពេញបំណងវាដោយសេរី ។ មេចោរព្រមទៅដេកក្នុងបន្ទប់ផ្ទះអាលី-បាបា, បន្ទាប់ពីអាលី-បាបាបានពោលបង្ខំជាញឹកញយ ។

ជនជាម្ចាស់ផ្ទះនៅអង្គុយនិយាយលេងនឹងភ្ញៀវពីនេះពីនោះ លុះត្រាតែនាងមរ្សីយ៉ានលើកបាយមកដល់ ។ វាលាភ្ញៀវចេញទៅនៅពេលដែលភ្ញៀវបាយរួចស្រួលបួល ។ មុននឹងលាភ្ញៀវចេញទៅ, វាពោលទៅកាន់ភ្ញៀវថា : "អញ្ជើញលោកសម្រាកកម្លាំងចុះ បើលោក



ត្រូវការអ្វី សូមលោកសួររកកុំញញើតអ្វី, នៅផ្ទះខ្ញុំគ្មានអ្វីនឹងខ្វះទទួលលោកទេ" ។

មេចោរក៏ក្រោកឡើង ជូនអាលី-បាបារហូតដល់មាត់ទ្វារ ។ ហើយនៅពេលដែលអាលី-បាបាចូលទៅផ្ទះបាយ ដើម្បីនិយាយនឹងនាងមរ្សីយ៉ាន, មេចោរក៏ចូលទៅក្នុងទីធ្លា, ធ្វើជាទៅអើតមើលក្រោលតើលាខ្លួនបានអ្វីស៊ីគ្រប់គ្រាន់ហើយឬនៅ ។

អាលី-បាបា បន្ទាប់ពីផ្ដាំនាងមរ្សីយ៉ានម្ដងទៀតថា ឱ្យមើលបម្រើភ្ញៀវឱ្យត្រឹមត្រូវផង, ហើយកុំឱ្យខ្វះអ្វីឱ្យសោះ, ក៏ពោលបន្ថែមប្រាប់នាងទៀតថា : "មរ្សីយ៉ាន, ស្អែកនេះ អញនឹងទៅកាន់កន្លែងមុជទឹកឱ្យបានដល់មុនពេលថ្ងៃរះ ។ ចូរឯងមើលរៀបចំខោ-អាវសម្រាប់មុជទឹករបស់អញឱ្យស្រួល ហើយប្រគល់ទៅឱ្យ អាប់ដាល្លា (Abdalla) (គឺជាឈ្មោះទាសាររបស់វា), រួចស្ងោរស៊ុបឱ្យឆ្ងាញ់ទុកឱ្យអញ ដើម្បីអញមកវិញនឹងស៊ីឱ្យមានកម្លាំង" ។ លុះពោលបង្គាប់នាងទាសីដូច្នេះរួច, វាក៏ចូលទៅនិទ្រាទៅ ។

មេចោរកាលចេញពីក្រោលមកវិញ ក៏ទៅបង្គាប់បញ្ជាកូនចោរថា ត្រូវធ្វើយ៉ាងណានោះ ចាប់តាំងពីឪទីនទីមួយ រហូតដល់ឪទីនក្រោយបង្អស់ ។ វាពោលទៅកាន់អាកូនចោរម្នាក់ៗថា : "កាលបើឮបោះដុំគ្រួសតូចចេញពីបន្ទប់ ដែលវានៅនោះ កុំភ្លេចនឹងយកកាំបិតដែលនៅនឹងខ្លួន វះឪទីនតាំងពីមាត់លើមកទាល់បាតចេញមក ។ ខ្ញុំនឹងមកដល់អ្នកភ្លាមនៅពេលនោះ" ។

កាំបិតដែលអាចោរពោលនោះ មានមុខតូចរៀវហើយមុតណាស់ ។

ពោលសព្វគ្រប់ដូច្នោះហើយ វាក៏ត្រឡប់មកវិញ ។ កាលបើមកដល់មាត់ទ្វារផ្ទះបាយភ្លាម, នាងមរ្ជីយ៉ានក៏យួរចង្កៀងនាំអាមេចោរទៅក្នុងបន្ទប់ ដែលនាងបានរៀបជាស្រេច រួចនាងក៏ថយចេញទៅក្រោយពីបានសួរភ្ញៀវក្លែងក្លាយថា មានត្រូវការអ្វីទេ ។ ដើម្បីកុំឱ្យគេមានការសង្ស័យ មេចោរក៏រំលត់ចង្កៀង រួចប្រះដេកទាំងសម្លៀកបំពាក់, ប្រុងតែងើបឡើងនៅពេលភ្ញាក់ពីដំណេកលើកដំបូង ។

នាងមរ្ជីយ៉ាន ឥតភ្លេចពាក្យបណ្តាំអាលី-បាបាឡើយ ។ នាងរៀបចំសម្លៀកបំពាក់សម្រាប់មុជទឹក, រួចប្រគល់ទៅអាប់ដាល្លា ដែលពុំទាន់ចូលទៅគេងនៅឡើយ ។ នាងដាំឆ្នាំងទៅលើចង្ក្រានដើម្បីរៀបចំស្ងោរស៊ុប ។ នៅពេលនាងកំពុងដួសពពុះចេញពីឆ្នាំង ចង្កៀងក៏រលត់នៅក្នុងផ្ទះប្រេងក៏អស់ទៀនក៏គ្មាន ។ តើធ្វើដូចម្តេច? ព្រោះនាងត្រូវការពន្លឺ ដើម្បីដួសពពុះចេញពីឆ្នាំង ។ នាងក៏និយាយប្រាប់អាប់ដាល្លា ។ អាប់ដាល្លាក៏ពោលឡើងថា : “រឿងប៉ុណ្ណឹងក៏លំបាកដែរ មរ្ជីយ៉ានឯងម្តេចក៏មិនទៅដួសយកប្រេងក្នុងឪទឹន ដែលនៅក្នុងទីធ្លានោះបន្តិចមក” ។

មរ្ជីយ៉ានក៏អរគុណអាប់ដាល្លា ។ ដូច្នោះនៅពេលដែលអាប់-ដាល្លាចូលទៅគេងជិតបន្ទប់អាលី-បាបា ដើម្បីនឹងភ្ញាក់តាមវាទៅឯ



កន្លែងមុជទឹក, នាងមរ្ជីយ៉ានក៏កណ្តៀតក្អមដាក់ប្រេងចេញទៅទីធ្លា ។ លុះនាងទៅដល់ជិតឪទឹនទីមួយ កូនចោរដែលពួននៅក្នុងឪទឹនក៏សួរមកនាងតិចៗថា : “ដល់ពេលហើយឬ” ។

ពិតមែនតែចោរនិយាយតិចៗ ប៉ុន្តែមរ្ជីយ៉ានបានស្តាប់ឮយ៉ាងច្បាស់ ព្រោះមេចោរកាលបើដាក់ជំនិះចេញពីលើខ្នងលារួចហើយ បានបង្ហើបមាត់ឪទឹនគ្រប់ទាំងអស់ ។ ដើម្បីឱ្យជននៅខាងក្នុងបានខ្យល់ដកដង្ហើមស្រួល ។

គ្រប់ទាសីទាំងអស់ក្រៅពីមរ្ជីយ៉ាន, ប្រាកដជាភ្ញាក់ផ្អើលភ័យស្រឡាំងកាំង ស្រែកឆោឡោ ដែលជាហេតុបណ្តាលឱ្យទៅជាមានគ្រោះ កាលបើមិនឃើញឯប្រេងដូចចិត្ត ត្រឡប់ជាឃើញមនុស្សនៅក្នុងឪទឹនដូច្នេះវិញ ។ ប៉ុន្តែនាងមរ្ជីយ៉ានជាស្ត្រីមានគុណភាពលើសស្ត្រីទាំងនោះ នាងយល់មួយរំពេចភ្លាមនូវសារសំខាន់នៃការណ៍អាថ៌កំបាំងនៃគ្រោះថ្នាក់ទន់ហាន់ដែលអាលី-បាបា គ្រួសារ និងខ្លួននាងផ្ទាល់ត្រូវទទួល ។ មិនតែប៉ុណ្ណោះ, នាងស្គាល់ដល់ការចាំបាច់ដែលត្រូវរកថ្នាំយ៉ាងប្រញាប់មកដាក់រោគនេះ ហើយកុំបាច់ឱ្យលាន់ឮសម្លេងទៅក្រៅផង ។ ដោយប្រាជ្ញាវៃរបស់នាងៗក៏នឹកឃើញភ្លាម នូវមធ្យោ-បាយសម្រាប់ប្រើក្នុងរឿងនេះ ។ គ្មានសម្តែងអាការៈភ័យតក់ស្លុតបន្តិច, នាងក៏តាំងខ្លួនជាមេនៃចោរទាំងនោះ ហើយឆ្លើយនូវសំនួររបស់វាថា “នៅទេ, ប៉ុន្តែជិតដល់ហើយ” ។ បន្ទាប់មក នាងក៏ដើរទៅ

ជិតឳទឹនមួយទៀត សំនួរដដែលក៏រត់មកប៉ះនឹងសោតបសាទនាង ។ មរ្សីយ៉ានដើរពីឳទឹនមួយទៅឳទិនមួយលុះត្រាតែដល់ឳទឹនចុងក្រោយបំផុត ដែលមានប្រេងពេញ ហើយសំនួរដដែលនៃចោរ បានត្រូវនាងឆ្លើយតបជាចម្លើយដដែលៗដែរ ។

អាស្រ័យហេតុនោះ, មរ្សីយ៉ានក៏បានដឹងថា អាលី-បាបាចៅហ្វាយរបស់នាងយល់ថា វាបានឱ្យផ្ទះសំណាក់តែដល់អ្នកជំនួញប្រេងម្នាក់ទេ, វាពុំបានដឹងថា វាបានបើកឱ្យចោរ៣៨ នាក់, រាប់ទាំងអ្នកជំនួញក្លែងក្លាយជាមេចោរចូលមកសំណាក់ផងឡើយ ។ ដូច្នេះនាងក៏ប្រញាប់ប្រញាល់ដងប្រេងពីឳទឹនក្រោយបំផុតដាក់ក្អមនាងឱ្យបានពេញ រួចនាងក៏ត្រឡប់ចូលទៅផ្ទះបាយវិញ យកប្រេងចាក់ដាក់ចង្កៀងហើយអុជឱ្យឆេះឡើង ។ តមកទៀត នាងក៏កាន់ខ្ទះដែកមួយធំចេញទៅទីធ្លា, ចាក់ប្រេងដាក់ពេញ កណ្ដៀតខ្ទះយកមកវិញនាងយកទៅដាក់លើចង្ក្រាន រួចក៏តាំងដាក់ឧសដុតយ៉ាងច្រើន ព្រោះថា ដរាបណាប្រេងពុះភ្លាម, ដរាបនោះនាងនឹងបានបំពេញកិច្ចនាងភ្លាមដែរ, ដែលជាកិច្ចអាចជួយសង្គ្រោះជីវិតមនុស្សម្នាទាំងអស់នៅក្នុងផ្ទះ ។ ទីបំផុតប្រេងក៏ពុះដូចចិត្ត, នាងលើកខ្ទះនោះឡើងហើយយកទៅចាក់លើឳទឹនគ្រប់ទាំងអស់ ចាប់តាំងពីឳទឹនទីមួយ រហូតដល់ឳទឹនក្រោយបង្អស់ដើម្បីនឹងសម្លាប់ចោរទាំងនោះ ។

ដោយសេចក្ដីក្លាហាននៃនាងមរ្សីយ៉ាន, កិច្ចនេះក៏បានសម្រេច



ដោយសេចក្ដីស្ងៀមស្ងាត់ ដូចបំណងនាង ។ ទាសីក៏ត្រឡប់ចូលមកផ្ទះបាយវិញ ដៃកាន់ខ្ទះទទេ ហើយទាញទ្វារបិទទៅ ។ នាងលត់ភ្លើងចង្ក្រានចេញខ្លះ ទុកនៅតែភ្លើងល្មមនឹងចម្អិនស៊ុបអាលី-បាបា ។ បន្ទាប់មក, នាងក៏លត់ចង្កៀង ហើយអង្គុយសម្ងំនៅស្ងៀមសម្រេចចិត្តថានឹងចូលនិទ្រា លុះត្រាតែបានឃើញរឿងដែលនឹងកើតឡើង ។ នាងអង្គុយចាំមើលព្រឹត្តិការណ៍តាមបង្អួចផ្ទះបាយ ដែលបើកចំហទៅរកទីធ្លាដែលរាត្រីងងឹតអនុញ្ញាតឱ្យនាងមើលឃើញបានល្មម ។

នាងមរ្សីយ៉ានអង្គុយចាំមើលមិនទាន់បាន១៥ នាទីផង, ស្រាប់តែមេចោរភ្ញាក់ឡើង ។ វាក្រោកឈរសម្លឹងមើលតាមបង្អួចដែលវាបើក ។ កាលបើវាសង្កេតមើលឥតមានឃើញពន្លឺអ្វីទេ ទាំងអាការៈក្នុងផ្ទះក៏ស្ងប់ស្ងៀមឈឹង វាក៏ឱ្យសញ្ញា ដោយបោះដុំគ្រួសតូចៗទៅដី, ដែលភាគច្រើនបានធ្លាក់ទៅលើឳទឹន ។ វាក៏ចំហប្រុងស្ដាប់ការ, ប៉ុន្តែវាឥតបានឮឬឃើញអ្វីបន្តិច ដែលអាចឱ្យសម្គាល់បានថា ពួកវាកំពុងធ្វើចលនា ។ មេចោរក៏នឹកបារម្ភភ្លាម វាចាប់បោះគ្រាប់គ្រួសជាលើកទីពីរទីបីទៀត, គ្រាប់គ្រួសក៏បានធ្លាក់ទៅលើឳទឹន, ប៉ុន្តែគ្មានចោរណាម្នាក់កម្រើកសោះ។ មេចោរក៏ពុំយល់ហេតុផលអ្វីសោះ ទើបវាចុះទៅទីធ្លា ដោយសេចក្ដីភិតភ័យ ។ វាក៏ដើរទៅជិតឳទឹនទីមួយ ហើយកាលបើវាចង់សួរទៅកូនចោរដែលវាយល់ថានៅរស់, តើវាដេកលក់ឬ, វាក៏ធុំក្លិនប្រេងដែលនៅក្ដៅចេញពីក្នុងឳទឹនមក ។ ទើបវាយល់ថា

ផែនការរបស់វាដែលប្រុងសម្លាប់និងប្លន់ផ្ទះអាលី-បាបា ដើម្បីបើ
អាចធ្វើបាន, ជញ្ជូនយកមាសដែលអាលី-បាបាបានលួចពីឃ្លាំងវាយក
ទៅវិញ ត្រូវវិនាសអន្តរាយ ។ មេចោរបានដើរមើលគ្រប់ឪទីនទាំង-
អស់, ក៏បានឃើញថា កូនចោររបស់វាស្លាប់អស់ហើយ ។ ឯប្រេងក៏
នៅសល់តិច, សឱ្យឃើញនូវមធ្យោបាយដែលគេប្រើដើម្បីកាត់ដៃ
កាត់ជើងវា កុំឱ្យមាននរណាអាចមកជួយបាន ។ អស់សង្ឃឹមវាក៏រត់
គេចខ្លួនតាមមាត់ទ្វារសួន, ឆ្លងពីសួនមួយទៅសួនមួយ ដោយឡើង
ផ្លោះតាមរបង ។

កាលបើនាងមរ្ជីយ៉ានបាត់ឮសូរអ្វីទាំងអស់ ហើយមិនឃើញ
មេចោរត្រឡប់មកវិញ, នាងក៏ឥតឆ្ងល់នូវផ្លូវដែលមេចោររត់គេចខ្លួន
ដែរ, ព្រោះទ្វារផ្ទះចាក់សោដល់ទៅពីរជាន់ឯណោះ ។ នាងក៏រីករាយ
សប្បាយចិត្ត ដោយបានញ៉ាំងផ្ទះទាំងមូលឱ្យនៅក្នុងសេចក្តីរៀបរយ
ហើយនាងក៏ចូលទៅគេងលក់ទៅ ។

ចំណែកអាលី-បាបា, វាក៏បានចេញពីផ្ទះតាំងពីពេលមុនថ្ងៃរះ,
សំដៅទៅកន្លែងមុជទឹកជាមួយទាសាវា ដោយឥតបានជ្រាបព្រឹត្តិ-
ការណ៍បន្តិចនៅក្នុងផ្ទះវា នៅពេលដែលវាកំពុងនិទ្រាលក់ ។ រឿងនេះ
នាងមរ្ជីយ៉ានពុំបានដាស់វាប្រាប់ទេ ព្រោះនាងមានវិចារណញ្ញាណ
គិតរកផ្លូវត្រូវឃើញមួយរំពេចនៅពេលមានអាសន្ន ។ ដូច្នោះ, នាង
យល់ឃើញថា ជាការឥតប្រយោជន៍នឹងទៅរំខានវាឱ្យខានដេកនៅ ។



លុះអាលី-បាបា ត្រឡប់ពីកន្លែងមុជទឹក ចូលមកដល់ក្នុងផ្ទះ,
ពេលនោះព្រះអាទិត្យបានរះហើយ វាមានសេចក្តីងឿងឆ្ងល់ជាក្រៃ-
លែង ដោយឃើញឪទីនប្រេងនៅនឹងកន្លែងទាំងអស់ ។ រីឯម្ចាស់លាក៏
ពុំឃើញនាំលាទៅឯផ្សារ ទើបវាសួរនូវការណ៍នេះទៅមរ្ជីយ៉ាន ដែល
បានមកបើកទ្វារឱ្យវា នឹងបានទុករបស់ទាំងឡាយនៅក្នុងសភាពដើម
ដដែល, ដើម្បីបង្ហាញទស្សនភាពដល់អាលី-បាបា និងដើម្បីពន្យល់
ដល់អាលី-បាបា អំពីកិច្ចដែលនាងបានធ្វើឱ្យជីវិតវាគង់នៅ ។

នាងមរ្ជីយ៉ានក៏ឆ្លើយប្រាប់ចៅហ្វាយខ្លួនថា : “ឱចៅហ្វាយ
អើយ ! ព្រះអាទិទេពទ្រង់បានទុកជីវិតលោកនិងអ្នកនៅក្នុងផ្ទះទាំង
ប៉ុន្មានឱ្យគង់នៅ លោកនឹងបានជ្រាបច្បាស់ជាងនេះនូវការអ្វីៗ ដែល
លោកចង់ដឹង, កាលបើខ្ញុំបង្ហាញលោកឱ្យឃើញវត្ថុផ្សេងៗ សូមអញ្ជើញ
មកតាមខ្ញុំមក” ។

អាលី-បាបា ក៏ដើរតាមនាងមរ្ជីយ៉ាន លុះបិទទ្វារផ្ទះស្រួល-
បួលហើយ នាងក៏នាំចៅហ្វាយខ្លួនទៅជិតឪទីនទីមួយ, រួចពោលថា :
“សូមលោកមើលក្នុងឪទីននេះ, តើមានប្រេងទេ” ។

អាលី-បាបា ក៏ឈ្ងោកមើល ប៉ុន្តែដោយវាឃើញមនុស្សនៅក្នុង
នោះទៅវិញ, វាក៏ដាក់មេថយយ៉ាងប្រញាប់, ភ័យស្រែកភ្លាត់សម្លេង
ញ័រមាត់ញ័រកស្ទើរតែនឹងស្លាប់ ។ នាងមរ្ជីយ៉ានក៏ប្រាប់ថា : “សូម
លោកកុំខ្លាចអ្វីឱ្យសោះ, មនុស្សដែលលោកឃើញនោះ មិនអាចធ្វើអ្វី

អាក្រក់ដល់ខ្លួនលោកបានទេ ។ វាប្រុងនឹងធ្វើមែន, ប៉ុន្តែឥឡូវនេះ, វាអស់សមត្ថភាពនឹងធ្វើអាក្រក់ដល់ខ្លួនលោក ឬក៏ជនណាដទៃទៀយ គឺវាទៅស្រុកដើមហើយ” ។

- មរ្ជីយ៉ាន ! (អាលី-បាបាស្រែក) ការណ៍ដែលឯងបានបង្ហាញឱ្យអញមើលទាំងប៉ុន្មាន តើមានន័យដូចម្ដេច ចូរឯងពន្យល់ប្រាប់អញភ្លាមមក ។

- ខ្ញុំនឹងពន្យល់ប្រាប់លោកឥឡូវនេះហើយ, តែសូមលោកកុំភ្ញាក់ផ្អើលខ្លាំងពេក, ក្រែងអ្នកជិតខាងគេដឹងរឿងដ៏សំខាន់នេះ ដែលលោកត្រូវលាក់ឱ្យជិត ។ ដំបូងបង្អស់, សូមលោកពិនិត្យមើលឪទីនឯទៀតសិន ។

អាលី-បាបា ក៏ដើរមើលឪទីនតាំងពីដើមបង្អស់រហូតដល់ឪទីនចុងប៉ូចបំផុត, ដែលដាក់ប្រេងសុទ្ធមែនៗ ។ វាសង្កេតឃើញប្រេងនៅក្នុងឪទីនខាងក្រោយនេះរលោះជាច្រើន ។ កាលបើវាបានមើលឪទីនគ្រប់អស់ហើយ វាទៅជានៅឈរទ្រឹងនឹងស្លុកស្រឡាំងកាំង ជូនកាលសម្លឹងទៅជើង ជូនសម្លឹងមើលទៅនាងមរ្ជីយ៉ាន ឥតពោលអ្វីមួយម៉ាត់ឡើយ ព្រោះសេចក្ដីភ្ញាក់ផ្អើលរបស់វា ធំរកអ្វីប្រៀបពុំបាន ។ ទីបំផុត, កាលបើវាស្ដីឡើងវិញ វាក៏សួរថា : “ចុះឈ្មួញនោះ ទៅជាយ៉ាងម៉េចទៅ?”

ឈ្មួញនោះ ជាឈ្មួញចាញ់ឈ្មួញខ្ញុំទៅទៀត (មរ្ជីយ៉ាន), ខ្ញុំ



នឹងនិយាយប្រាប់លោកថា វាជាយ៉ាងម៉េចនឹងទៅជាយ៉ាងម៉េច, ប៉ុន្តែចាំលោកត្រឡប់ចូលទៅក្នុងបន្ទប់លោកសិន, ព្រោះដល់ពេលលោកត្រូវទទួលទានស្ងោរស៊ុបហើយ ដើម្បីឱ្យមានកម្លាំងបន្ទាប់ពីបានអញ្ជើញមកពីកន្លែងមុជទឹក ។

នៅពេលអាលី-បាបា ដើរចូលទៅក្នុងបន្ទប់ នាងមរ្ជីយ៉ានក៏ចូលទៅក្នុងផ្ទះបាយ លើកស៊ុបមកជូនចៅហ្វាយខ្លួន ។ មុននឹងអាស្រ័យស៊ុប អាលី-បាបាក៏និយាយទៅកាន់ទាសីថា : “ចូរឯងនិយាយរឿងដ៏ចម្លែកប្រាប់អញឱ្យសព្វគ្រប់មកមើល” ។

មរ្ជីយ៉ាន ដើម្បីគោរពដល់ចៅហ្វាយរបស់ខ្លួនក៏ចាប់រៀបរាប់ឡើងថា : “លោកជាចៅហ្វាយ, ពីម្សិលមិញ វេលាល្ងាច, កាលបើលោកចូលសម្រាន្តទៅ ខ្ញុំក៏នៅរៀបចំសម្លៀកបំពាក់សម្រាប់មុជទឹករបស់លោកតាមបង្គាប់ ហើយខ្ញុំក៏បានប្រគល់ឱ្យទៅអាប់ដាល្លា” ។ តមកទៀត, ខ្ញុំក៏ដាំឆ្នាំងស្ងោរស៊ុប ។ នៅពេលខ្ញុំកំពុងដួសពពុះចេញ, ចង្កៀងដោយមកពីអស់ប្រេង ក៏រលត់មួយរំពេច ហើយនៅក្នុងក្អមរកប្រេងមួយដំណក់គ្មាន ឯកន្ទុយទៀនក៏រកពុំបាន ។ អាប់ដាល្លាឃើញខ្ញុំអន្ទះអន្ទែងរកអ្វីពុំឃើញដូច្នោះ, ក៏នឹកឃើញប្រាប់ខ្ញុំអំពីឪទីនប្រេងនៅកណ្ដាលទីធ្លា ។ ខ្ញុំក៏កន្ត្រាក់យកក្អមប្រញាប់ប្រញាល់តម្រង់ទៅឪទីនប្រេងដែលនៅជិតជាងគេ ។ ប៉ុន្តែកាលបើដើរទៅដល់ជិតឪទីន, សម្លេងមួយក៏សួរមកខ្ញុំថា : “ដល់ពេលហើយឬ?” ។ ខ្ញុំក៏ឥតញញើត

អ្វីឡើយ ហើយក៏យល់មួយរំពេច នូវអំពើពុតពាលនៃអ្នកជំនួញក្លែងក្លាយ ទើបឆ្លើយដោយឥតញញើតថា : "នៅទេ. ប៉ុន្តែបន្តិចទៀត" ខ្ញុំក៏ដើរទៅជិតឪទីនមួយទៀត. សម្លេងដដែលក៏បញ្ចេញសំនួរដដែលមកទៀត. ហើយខ្ញុំក៏ឆ្លើយតែដដែលទៀត ។ ដើម្បីឱ្យអស់ចិត្ត. ខ្ញុំក៏ដើរទៅជិតឪទីនគ្រប់ទាំងអស់ សំនួរក៏នៅតែដដែល. ចម្លើយក៏នៅតែដដែល ។ លុះត្រាតែដល់ឪទីនខាងក្រោយបង្អស់ ទើបខ្ញុំរកប្រេងបាន។ ពេលនោះខ្ញុំសម្គាល់ឃើញថា មានចោរ៣៧នាក់នៅកណ្ដាលទីធ្លាផ្ទះលោកចោរទាំងនោះនៅរង់ចាំតែសញ្ញាឬបង្គាប់ពីចៅហ្វាយវា. ដែលលោកយល់ថាជាអ្នកជំនួញពិតប្រាកដ ហើយដែលលោកបានធ្វើបដិសណ្ឋារកិច្ចយ៉ាងជ្រាលជ្រៅផង ដើម្បីកម្ទេចផ្ទះលោកឱ្យម៉ត់ទៅជាផេះ។ កាលបើបានឃើញដូច្នេះហើយ ខ្ញុំក៏ឥតបង្អង់ឱ្យយូរពេលឡើយ. ខ្ញុំកាន់ក្អមយកមកវិញ. អុជចង្ក្រានឱ្យឆេះឡើង រួចយកខ្ទះដែកមួយយ៉ាងធំទៅដាក់ប្រេងពេញ ។ តមក. ខ្ញុំក៏យកឆ្នាំងខ្ទះនោះដាក់ដាំលើចង្ក្រាន ។ កាលបើប្រេងពុះហើយ. ខ្ញុំក៏លើកយកទៅចាក់ដាក់លើគ្រប់ឪទីនទាំងអស់ ដែលមានចោរនៅក្នុងនោះ ដើម្បីរាំងរាចោរទាំងនោះ កុំឱ្យវាបំពេញបំណងរបស់វាបាន ។ កិច្ចនេះក៏ហើយត្រឹមនេះ. ខ្ញុំក៏ត្រឡប់ទៅផ្ទះបាយវិញ ហើយលត់ចង្កៀងចេញសិន មុននឹងចូលទៅទទួលទានដំណេក. នាងខ្ញុំអង្គុយពិនិត្យយ៉ាងស្ងៀមស្ងាត់តាមបង្អួចតើអ្នកជំនួញក្លែងក្លាយប្រើកិច្ចកលយ៉ាងម៉េច។ មួយសន្ទុះក្រោយមក.



ដើម្បីជាសញ្ញា ខ្ញុំក៏ឮមេចោរបោះគ្រាប់គ្រួសតាមបង្អួចធ្លាក់ទៅលើឪទីនទាំងឡាយ ។ វាបានបោះជាលើកទីពីរទីបី ហើយដោយវាឥតឃើញឬឮសូរមនុស្សកម្រើកខ្លួនបន្តិចសោះ. វាក៏ចុះទៅដី។ ខ្ញុំបានតាមមើលឃើញវាដើរពីឪទីនមួយទៅឪទីនមួយ លុះដល់ឪទីនក្រោយបំផុត។ បន្ទាប់ពីនោះរាត្រីងងឹតបានធ្វើឱ្យខ្ញុំមើលអ្វីលែងឃើញទៅ ។ លុះខ្ញុំអង្គុយចាំមើលមិនឃើញវាត្រឡប់មកវិញ. ខ្ញុំក៏ដឹងច្បាស់ថា មេចោរបានរត់គេចខ្លួនតាមសួន. អស់សង្ឃឹមនឹងផែនការសម្ងាត់របស់វាមិនបានសម្រេច ។ ដូច្នោះ. ខ្ញុំក៏ទទួលទានដំណេកទៅ. ជឿជាក់ប្រាកដថាទីផ្ទះបានសេចក្ដីសុខហើយ ។

ជាទីបញ្ចប់. នាងមរ្សីយ៉ានបន្ថែមថា : "នេះហើយជារឿងដែលលោកសួរខ្ញុំ ហើយរឿងនេះ ជារឿងដែលកើតមានឡើងបន្តពីរឿងមុន ដែលខ្ញុំបានសង្កេតឃើញតាំងពីពីរបីថ្ងៃមកហើយ ប៉ុន្តែខ្ញុំពុំទាន់ហ៊ានជម្រាបលោក" ។ រឿងនោះ គឺយ៉ាងនេះ នៅពេលមួយ. ព្រលឹមស្រាងៗ ខ្ញុំបានត្រឡប់មកពីទីក្រុងស្រាប់តែឃើញមាត់ទ្វាររបងមានគូសសញ្ញាស ។ ថ្ងៃបន្ទាប់មកបាត់ឯសញ្ញាស. លេចឯសញ្ញាក្រហម។ ហើយនៅគ្រប់ពេលដែលខ្ញុំប្រទះនោះ ខ្ញុំក៏យកដីសគូសតាមគេលើទ្វារផ្ទះអ្នកជិតខាង ត្រង់កន្លែងតែមួយដែរ. ទាំងខាងលើទាំងខាងក្រោម. ដោយឥតបានដឹងថា គំនូសដែលគេគូសនោះ គេមានបំណងនឹងធ្វើអ្វីផង ។ បើសិនជាលោកយករឿងដែលកើតក្រោយនេះ

ទៅថ្លឹងមើលជាមួយនឹងព្រឹត្តិការណ៍ខាងដើម, នោះលោកនឹងឃើញថា រឿងទាំងនេះចេញមកតែពីប្រភពចោរព្រៃតែមួយ, តែខ្ញុំពុំដឹងថា តើហេតុអ្វីបានជាក្រុមនេះថយចំនួនមនុស្សពីរនាក់ ។ តែទោះជាយ៉ាងម៉េចក៏ដោយយើងសន្មតថា ឥឡូវក្រុមចោរនោះបាត់មនុស្សដល់ទៅបី ជាហេតុឱ្យយើងដឹងថា វានឹងធ្វើកិច្ចបំផ្លាញជីវិតលោកថ្ងៃណាមួយទៀត។ ដូច្នោះសូមលោកប្រយ័ត្នខ្លួនឱ្យមែនទែន លោកគិតថា ទោះយ៉ាងម៉េចក៏គង់មានគ្នាវាម្នាក់ នៅរស់ក្នុងលោកនេះដែរ ។ ចំណែកខាងខ្ញុំៗឥតមានធ្វេសប្រហែសនឹងការពារខ្លួនលោកឡើយ ដូចជាខ្ញុំបានធ្វើមកជាស្រេច ។

កាលបើនាង មរ្យ៊ីយ៉ាន និយាយចប់ហើយ អាលី-បាបាយល់ថា ខ្លួនត្រូវជំពាក់គុណនាងច្រើនណាស់ ក៏និយាយថា : "អញនឹងមិនបណ្ដោយខ្លួនឱ្យស្លាប់ហួស ដោយឥតបានជូនរង្វាន់ជាទីគាប់ចិត្តដល់ឯងឡើយ អញនឹងបូជាជីវិតអញចំពោះឯង ។ ហើយជាដំបូង ដើម្បីជាភស្តុតាងក្នុងការតបគុណដល់ឯង អញសូមដោះលែងឯងពីភាពបាវព្រាវតាំងពីពេលនេះទៅ ។ អញយល់ច្បាស់ហើយថា ចោរទាំង៤០ បានធ្វើកលឧបាយ ដើម្បីនឹងសម្លាប់អញ តែព្រះអាទិទេពលោកបានជួយស្រោចស្រង់ជីវិតអញរួច ដោយសារមធ្យោបាយរបស់ឯង ។ អញនឹងសង្ឃឹមថា ព្រះអាទិទេពលោកនឹងចេះតែតាមជួយរក្សាអញទល់នឹងអំពើព្យាបាទ នៃពួកចោរទាំងនោះទៀតពុំខានឡើយ ។ ដូចជា



ព្រះអង្គបានជួយស្រោចស្រង់ពិភពលោកឱ្យផុតរួចពីការបំផ្លេចបំផ្លាញនៃពួកជននោះដែរ ។ ក្នុងខណៈនេះ កិច្ចដែលយើងត្រូវធ្វើ គឺយកសពជនអប្រិយទុយិសនេះទៅកប់ដោយសេចក្ដីស្ងប់ស្ងាត់ជាទីបំផុត កុំឱ្យជនណាម្នាក់មានសេចក្ដីសង្ស័យដល់វាសនារបស់វាបានឡើយ ។ ហើយចំពោះរឿងនេះ អញនឹងទៅបំពេញកិច្ចការជាមួយនឹងអាប់ដាល្លា" ។

សួនច្បាររបស់អាលី-បាបា, មានបណ្ដោយយ៉ាងវែង, ហើយនៅខាងចុងមានព្រៃឈើធំៗ ។ គ្មានបង្អែបង្អង់យូរ, អាលី-បាបាក៏ទៅកាន់ទីនោះ ជាមួយទាសាជីករណ្ដៅមួយ, មានបណ្ដោយនឹងទទឹងត្រូវតាមចំណុះខ្លួនមនុស្សដែលនឹងយកទៅកប់ ។ ដីសួនក៏ស្រណុកជីក, មិនយូរប៉ុន្មានជនទាំងពីរក៏ជីករណ្ដៅនោះរួច, ហើយក៏មកបបួលគ្នាទាញខ្មោចចេញពីក្នុងឪទីនដកយកគ្រឿងអាវុធចេញពីខ្លួន, រួចជញ្ជូនយកទៅដាក់តម្រៀបក្នុងរណ្ដៅ កាយដីលុបពីលើ ។ ដីដែលនៅសល់គេកើបយកទៅចាក់រាយពាសពេញទីនោះ ដើម្បីឱ្យផ្ទៃដីនៅរាបស្មើដដែលដូចពីពេលមុន ។ ឪទីនប្រេងនឹងគ្រឿងប្រហារជីវិត អាលី-បាបាយកទៅលាក់នៅកន្លែងមួយយ៉ាងត្រឹមត្រូវ ។ ចំណែកឯលាវិញដែលវាគ្មានត្រូវការយកទៅប្រើអ្វីក្នុងពេលនោះ ក៏បង្គាប់ឱ្យទាសារបស់វាយកទៅលក់ឯផ្សារមួយម្ដងៗ ។

នៅពេលដែល អាលី-បាបា កំពុងតែចាត់វិធានការ កុំឱ្យមានការសង្ស័យពីសាធារណជនអំពីមធ្យោបាយ ដែលវាបានទៅជាអ្នក

មានយ៉ាងឆាប់ដូច្នេះ មេចោរក៏បានត្រឡប់ចូលព្រៃវិញ ប្រកបដោយសេចក្ដីឈឺចាប់ខ្លោចផ្សាជាក្រៃលែង ។ វាចូលទៅក្នុងរូងប្រើខួរក្បាលគិតសព្វគិតគ្រប់ តាំងពីនៅតាមផ្លូវថាតើវាត្រូវធ្វើ ឬក៏ឈប់លែងធ្វើអ្វីទៅលើរូបអាលី-បាបាទៀត ។

នៅក្នុងរូងងងឹត ដែលចោរនៅនោះ មានអាការៈស្ងប់ស្ងាត់គួរឱ្យវាខ្លាចណាស់. ទើបវាស្រែកពោលឡើងថា: “ជនក្លាហានទាំងឡាយអ្នកជាសហជីវិនរបស់ខ្ញុំក្នុងការយាមល្បាត. ក្នុងការប្រដេញ និងក្នុងការប្រតិបត្តិការ តើឥឡូវអ្នកនៅឯណា? តើខ្ញុំអាចធ្វើអ្វីបាន បើអត់អំពីអ្នក? ដើម្បីឱ្យអ្នកទៅស្លាប់ទាំងអស់គ្នាតែម្ដង ដោយវាសនាអាក្រក់បំផុត ហើយមិនសមនឹងចិត្តក្លាហានរបស់អ្នកដូច្នេះឬ? ខ្ញុំនឹងពុំសូវជាស្ដាយស្រណោះអាឡោះអាល័យប៉ុន្មានទេ. បើសិនជាខ្ញុំឃើញអ្នកស្លាប់ ដោយបានកាន់អាវុធប្រយុទ្ធនឹងដៃសមជាប្រុសអ្នកក្លាហាននោះ ។ កាលណាទៅហ្ន៎ ខ្ញុំនឹងបង្កើតក្រុមថ្មីទៀតបាន. ហើយឱ្យបានមនុស្សចិត្តមុតដូចអ្នកទៀតហ្ន៎? ហើយកាលបើខ្ញុំធ្វើបាន តើខ្ញុំអាចចាប់ធ្វើការឡើងវិញ. ការពារមាសប្រាក់ដ៏ច្រើនអនេកកុំឱ្យធ្លាក់ទៅជាចំណីនៃជនដែលបានលួចយកសម្បត្តិយើងខ្លះទៅធ្វើជាអ្នកមានទៅហើយបានឬទេ ? ខ្ញុំអាចធ្វើបាន. លុះត្រាតែដំបូងឡើយខ្ញុំសម្លាប់ជននោះឱ្យបានសិន បើខ្ញុំពុំអាចរកមនុស្សក្លាហានមកជួយបាន ក៏ខ្ញុំនឹងធ្វើតែម្នាក់ឯងដែរ ។ កាលបើខ្ញុំបានធ្វើឃ្លាំងខ្ញុំឱ្យគេចផុតពីការខ្លាចគេ



ប្លន់បានហើយ. ខ្ញុំក៏មិននៅស្ងៀម គឺខំធ្វើការយ៉ាងណាកុំឱ្យឃ្លាំងខ្ញុំឥតពីខ្ញុំទៅគ្មានអ្នកកាន់ការជំនួស. គ្មានម្ចាស់ឡើយ. គឺខ្ញុំត្រូវរក្សាឃ្លាំងខ្ញុំឱ្យគង់ ហើយឱ្យចេះតែចម្រើនតទៅទៀត” ។

កាលបើបានសម្រេចចិត្តដូច្នេះហើយ មេចោរក៏ឥតលំបាកនឹងរកមធ្យោបាយ ដើម្បីនឹងប្រតិបត្តិការតទៅទៀតដែរ ។ នៅពេលនោះ. ដោយសេចក្ដីសង្ឃឹមយ៉ាងមាំ នឹងដោយខួរក្បាលដ៏វៃរបស់វា មេចោរក៏ដេកលក់យ៉ាងស្កប់ស្កល់ក្នុងយប់នោះ ។

ស្អែកឡើង. មេចោរភ្ញាក់ពីព្រលឹមដូចចិត្តវាបានគិតទុក. ស្លៀកសំលៀកបំពាក់យ៉ាងស្អាតរួចក៏ទៅកាន់ទីក្រុង ។ វាចូលទៅស្នាក់ក្នុងផ្ទះសម្រាប់ពួកទូរចរ ។ នឹកសង្ឃឹមជានិច្ចក្នុងចិត្តថា រឿងហេតុដែលកើតមានក្នុងផ្ទះអាលី-បាបា ប្រាកដជាលេចឮទៅក្រៅពុំខានឡើយ ទើបវាសួរទៅនាយគេហបាល ជាពាក្យសន្ទនាធម្មតាថា តើមានការអ្វីចម្លែកទេនៅក្នុងទីក្រុង ។ នាយគេហបាលក៏ឆ្លើយពីរឿងដទៃផ្សេងខុសពីរឿងដែលវាចង់ដឹង ។ មេចោរត្រិះរិះឃើញនូវហេតុដែលអាលី-បាបា ខំលាក់ការអាថិកំបាំងយ៉ាងជិតដូច្នេះ គឺវាមិនចង់ឱ្យអ្នកនគរដឹងថា វាមានឃ្លាំងមាស ឃ្លាំងប្រាក់ ហើយនឹងមធ្យោបាយសម្រាប់ចូលផង។ ម្យ៉ាងទៀត វាក៏មិនមែនជាអ្នកល្ងង់ដែរថា ព្រោះមកតែពីរឿងនេះហើយបានជាមានគេប៉ងបំផ្លាញជីវិតវា ។ ហេតុនេះហើយបានជាវាខំលាក់ការសម្ងាត់យ៉ាងនេះ ។

មេចោរនោះមានសេះមួយជាប់នឹងខ្លួនទៅផង ។ សេះនោះវាសម្រាប់ដឹកក្រណាត់ផ្សេងៗនឹងព្រែល្អៗពីឃ្លាំងមកកន្លែងសំណាក់ ។ វាបានធ្វើដំណើរទៅកាន់ព្រៃជាច្រើនដង តែប្រុងប្រយ័ត្នខ្លួនណាស់ដើម្បីកុំឱ្យគេស្គាល់កន្លែង ដែលវាទៅយករបស់ ។ កាលបើវាបានជញ្ជូនក្រណាត់វាមក ចំនួនសមល្មមតាមចិត្តវាហើយ, ដើម្បីនឹងលក់របស់នោះ, វាក៏ដើររកហាងជំនួញ ហើយបានឃើញហាងមួយដូចចិត្ត។ រួចក្រោយដែលបាននិយាយជួលហាងនោះ ត្រូវថ្លៃគ្នាស្រួលបួលជាមួយនឹងម្ចាស់គេហើយ, វាក៏ជញ្ជូនក្រណាត់យកទៅដាក់ ហើយតាំងទីរកស៊ីនៅកន្លែងនោះ។ ហាងមួយនៅទល់មុខហាងវានោះគឺជាហាងរបស់កាស៊ីម, ប៉ុន្តែទើបតែនឹងបានទៅកូនប្រុសអាលី-បាបាកាន់កាប់ ។

មេនៃចោរសែសិប បានប្រែឈ្មោះថា កូស៊ីយ៉ាហុស្សាំង (Cogia Houssain) ។ ជាទម្លាប់នៃជនអ្នកចូលមករកស៊ីថ្មី, វាក៏ចាប់ធ្វើការទាក់ទងរាប់អានអ្នកជំនួញជិតខាងគ្នា ។ ប៉ុន្តែដោយកូនអាលី-បាបាមានវ័យនៅក្មេង, ប្រកបដោយឫកពាសមរម្យជាអ្នកមានប្រាជ្ញា, ហើយមេចោរក៏មានឱកាសញឹកញាប់និយាយជាមួយវាជាងអ្នកឯទៀត, វាក៏បានទៅជាមិត្រស្និទ្ធស្នាលជាមួយនឹងកូនអាលី-បាបា ។ មេចោរបានខំយកចិត្តទុកដាក់ បណ្ដុះសតិស្មារតីយុវពាណិជនោះជាក្រៃលែង, មិនយូរប៉ុន្មានចំនួនជាបីបួនថ្ងៃក្រោយមក, វាក៏បានឃើញអាលី-បាបានៅពេលដែលវាមកលេងកូនវា ។ អាលី-បាបាបានឈប់និយាយលេង



ជាមួយនឹងចោរតាមធម្មតា ដែលវាធ្លាប់មានការប្រស្រ័យនឹងជននានាមក ។ លុះអាលី-បាបាលាចេញទៅ, មេចោរក៏បានស្គាល់ថា អាលី-បាបានេះជាឪពុករបស់យុវពាណិជ ។ បានដឹងដូច្នេះ, វាក៏រឹតតែខំយកចិត្តយកថ្លើមលួងលោមយុវពាណិជដោយឱ្យនេះនោះបន្តិចបន្តួច ហើយថែមទាំងបានជប់លៀងពាណិជក្មេងជាច្រើនដងទៀត ។

កូនប្រុសអាលី-បាបា មិនមែនព្រងើយនឹងកិច្ចដែលកូស៊ីយ៉ា-ហុស្សាំងបានធ្វើដល់ខ្លួនទេ, ហើយខ្លួនមិនគិតធ្វើអ្វីជាការតបគុណដល់គេនោះឡើយ ។ ប៉ុន្តែដោយផ្ទះខ្លួននៅនោះចង្អៀតពេក, ហើយគ្មានគ្រឿងប្រើប្រាស់សព្វគ្រប់ ដើម្បីរៀបចំលៀងគេវិញតាមចិត្តប្រាថ្នាបាន។ ទើបថ្ងៃមួយវានិយាយអំពីបំណងរបស់វានោះប្រាប់អាលី-បាបាជាឪពុក ដោយពោលបញ្ជាក់ប្រាប់ឪពុក អំពីសេចក្ដីស្នោះសរបស់កូស៊ីយ៉ា-ហុស្សាំងមានមកលើខ្លួន ។

អាលី-បាបា ក៏ព្រមរៀបចំការជប់លៀងនោះដោយរីករាយ, ទើបនិយាយទៅកាន់កូនថា : “កូនប្រុសឪពុក, ស្អែកនេះជាថ្ងៃសុក្រ នៅថ្ងៃសុក្រនេះអ្នកជំនួញធំៗទាំងឡាយ, ដូចជាកូស៊ីយ៉ា-ហុស្សាំងក្ដី កូនឯងក្ដី គេតែងបិទហាងឈប់ធ្វើការទាំងអស់ ។ ដូច្នោះ នៅពេលស្រស់ស្រូបអាហារពេលព្រឹក រួចចូរកូនឯងបបួលគេដើរលេងយកខ្យល់អាកាសបន្តិចទៅ ។ លុះត្រឡប់មកវិញ, កូនឯងធ្វើយ៉ាងណាឱ្យបានគេដើរកាត់មុខផ្ទះឪពុក, រួចកូនឯងបបួលគេដើរចូលបណ្ដោយមក ។

ជាការប្រសើរត្រូវកូនឯងធ្វើយ៉ាងនេះ គឺកូនឯងអញ្ជើញគេបែបគ្រាន់តែជាការគួរសមប៉ុណ្ណោះ ។ ឪពុកនឹងបង្គាប់ឱ្យមវ្រឹយ៉ានរៀបចំបាយទឹកសម្រាប់ពេលល្ងាចទុកជាស្រេច" ។

លុះដល់ថ្ងៃសុក្រ, ពេលបាយរួច, កូនអាលី-បាបានឹងកូស៊ីយ៉ា-ហុស្សាំងក៏បានមកជួបតាមកន្លែងដែលគេបានណាត់គ្នា, រួចក៏បបួលគ្នាដើរលេង ។ លុះត្រឡប់មកវិញ, យុវពាណិជក៏នាំកូស៊ីយ៉ា-ហុស្សាំងដើរកាត់តាមផ្លូវមុខផ្ទះខ្លួន។ លុះមកដល់មុខផ្ទះ, កូនអាលី-បាបាក៏ឈប់ ហើយនិយាយទៅកាន់កូស៊ីយ៉ាថា : "នេះជាផ្ទះឪពុកខ្ញុំ, ហើយក្រោយពីខ្ញុំបាននិយាយប្រាប់គាត់អំពីមេត្រីភាពដែលលោកមានដល់ខ្ញុំ, គាត់ក៏បានផ្តាំខ្ញុំ ឱ្យអញ្ជើញលោកមកលេងផ្ទះគាត់ដោយកិត្តិយស ។ ខ្ញុំសូមអង្វរឱ្យលោកបន្ថែមការសប្បាយនេះទៅលើញាតិមិត្តខ្ញុំឯទៀតផង ដែលជាការសប្បាយដែលខ្ញុំត្រូវមានដល់លោក" ។

ពិតមែនតែកូស៊ីយ៉ា-ហុស្សាំង បានឈានជើងមកដល់ទីបំផុតនៃគោលបំណងវាហើយ, គោលបំណងដែលវាប្រាថ្នាឱ្យបានចូលទៅក្នុងផ្ទះអាលី-បាបា, ដើម្បីប្រហារជីវិតម្ចាស់ផ្ទះដោយស្ងាត់ៗ ប៉ុន្តែវាធ្វើជាប្រកែកពុំព្រមចូល, ហើយធ្វើជាសុំលាកូនអាលី-បាបាទៅវិញ ។ នៅពេលនោះ, ទាសាអាលី-បាបា ក៏ចេញមកបើកទ្វារ, កូនអាលី-បាបា ក៏ចាប់ទាញដៃមិត្តចាស់ដោយបង្ខំ លុះត្រាបានចូលទៅដល់ក្នុងផ្ទះ ។



អាលី-បាបា ចេញមកទទួលកូស៊ីយ៉ា-ហុស្សាំង ដោយទឹកមុខស្រស់ស្រាយ ហើយដោយកិច្ចរាក់ទាក់ណាស់ផង ។ គាត់បានថ្លែងអំណរគុណចំពោះភ្ញៀវ ដែលបានធ្វើអំពើល្អដល់កូនគាត់ដូច្នេះថា : "គុណបំណាច់ដែលកូនខ្ញុំនឹងខ្លួនខ្ញុំផ្ទាល់ ត្រូវមានដល់លោកជាគុណធំណាស់, ព្រោះកូនខ្ញុំជាយុវជននៅខ្ចីសេចក្តីនៅឡើយ ហើយលោកឥតមានប្រកាន់ខ្លួននឹងអប់រំទូន្មានបុត្រខ្ញុំឡើយ" ។

កូស៊ីយ៉ា-ហុស្សាំង បានសម្តែងគារវកិច្ចម្តងហើយម្តងទៀតដល់អាលី-បាបា, សូមធានាខ្លួនថា បើកូនគាត់ពុំទាន់មានការពិសោធគ្រប់គ្រាន់ ដូចជនខ្លះនោះទេ, ក៏វាជាមនុស្សប្រកបដោយសុភវិនិច្ឆ័យអាចជួយបង្ហាញការពិសោធរាប់ពុំអស់ដល់កូនគាត់ ។

បន្ទាប់ពីការសន្ទនាគ្នាអស់ពេលជាយូរក្រែល អំពីរឿងផ្សេងៗ កូស៊ីយ៉ា-ហុស្សាំង ក៏ចង់សុំលាម្ចាស់ផ្ទះ ។ ប៉ុន្តែអាលី-បាបាឃាត់ពុំព្រមឱ្យទៅ ដោយបានពោលថា លោក, តើលោកមានការអញ្ជើញទៅឯណាឬ? ខ្ញុំសូមអញ្ជើញលោកឱ្យនៅពិសាបាយជាមួយនឹងខ្ញុំម្តង ។ ម្ហូបអាហារដែលខ្ញុំនឹងរៀបទទួលលោកនោះមានសភាពអន់ថយពីម្ហូបអាហាររបស់លោក ធ្លាប់ទទួលទានណាស់, ប៉ុន្តែទោះជាម្ហូបនោះយ៉ាងម៉េចក៏ដោយ ក៏ខ្ញុំសង្ឃឹមថា លោកនឹងព្រមទទួលសេចក្តីអញ្ជើញខ្ញុំដោយស្មោះសរ ព្រោះជាបំណងរបស់ខ្ញុំយូរមកហើយ ។

- លោក ! កូស៊ីយ៉ា-ហុស្សាំងឆ្លើយ, ខ្ញុំស្គាល់ចិត្តថ្លើមល្អរបស់

លោកច្បាស់ណាស់ហើយ. ប៉ុន្តែបើសិនជាខ្ញុំពុំបានទទួលតាមសេចក្តី អញ្ជើញដ៏ស្មោះត្រង់របស់លោកនោះទេ. សូមលោកកុំយល់ថា ខ្ញុំជា មនុស្សឆ្មើងឆ្មៃឱ្យសោះ ខ្ញុំសូមឱ្យលោកយល់ដូច្នេះវិញថា ដែលខ្ញុំធ្វើ នេះ គឺមិនមែនខ្ញុំមានចិត្តប្រមាថមើលងាយលោកឬខ្វះសីលធម៌ចំពោះ លោកនោះទេ. ប៉ុន្តែខ្ញុំមានហេតុមួយ ដែលលោកឥតយល់ទាស់បាន. បើសិនជាលោកបានជ្រាប ។

- ចុះហេតុនោះយ៉ាងម៉េចទៅលោក? តើគេអាចសួរលោក បានទេ? ខ្ញុំអាចនិយាយជម្រាបលោកបាន។ ការណ៍នោះដូច្នេះ គឺខ្ញុំមិន ទទួលទានសាច់ ឬសម្លសាច់ដែលមានបង់អំបិលទេ។ សូមលោកជ្រាប ដោយខ្លួនលោកចុះ អំពីម្ហូបអាហារដែលខ្ញុំនឹងទៅរួមអាស្រ័យជាមួយ លោក ។ បើសិនជាលោកមានការតែប៉ុណ្ណោះទេ. លោកមិនគួរនឹង អាក់ខាននៅទទួលទានបាយនឹងខ្ញុំសោះ. មានតែលោកមិនចង់នៅអាស្រ័យជាមួយខ្ញុំតែម្តង ដោយទីមួយ នៅក្នុងនំប៉ុងដែលគេទទួលទាន ក្នុងផ្ទះខ្ញុំគ្មានអំបិលទេ. ហើយចំណែកឯសាច់នឹងសម្ល សាច់សម្រាប់ ដាក់ជូនលោក ខ្ញុំសូមសន្យាថា គ្មានអំបិលនៅក្នុងនោះទេ ។ ឥឡូវខ្ញុំ ចូលទៅបង្គាប់គេកុំឱ្យដាក់ ។ ហេតុនេះ សូមលោកកុំអញ្ជើញទៅណា ខ្ញុំត្រឡប់មកវិញឥឡូវនេះហើយ ។

អាលី-បាបា ក៏ចូលទៅក្នុងផ្ទះបាយ បង្គាប់នាងមរ្យ៉ានកុំឱ្យ ដាក់អំបិលក្នុងម្ហូប ដែលត្រូវលើកយកទៅជូនភ្ញៀវ ។



នាងមរ្យ៉ាន ដែលបានធ្វើម្ហូបឆ្អិនជាស្រេចហើយ. ក៏ពុំអាច ទប់ចិត្តមិនខឹងនឹងបង្គាប់ថ្មីនេះបានឡើយ. ទើបនាងនិយាយប្រាប់ អាលី-បាបាថា តើមនុស្សនោះជានរណា បានជាមិនអាស្រ័យអំបិលធ្វើ ឱ្យតែលំបាក បាយល្ងាចរបស់លោកពេលនេះពុំសូវឆ្ងាញ់ទេ បើសិនជា ខ្ញុំរៀបធ្វើថ្មីទៀត ។

សូមឯងកុំប្រញាប់ខឹងពេកមរ្យ៉ាន. គេជាមនុស្សស្លូតត្រង់ ទេតើ ។ សូមនាងធ្វើតាមតែខ្ញុំបង្គាប់ទៅ ។ មរ្យ៉ានធ្វើតាមបង្គាប់ ប៉ុន្តែដោយទើសទាល់។ នាងចង់ស្គាល់មនុស្សដែលមិនអាស្រ័យអំបិល នោះណាស់ ។ កាលបើនាងរៀបចំម្ហូបអាហាររួចស្រេចហើយៗអាប់ដាល្លាក៏រៀបតុហើយស្រេចដែរ. នាងក៏ជួយលើកម្ហូបអាប់ដាល្លា ។ លុះក្រឡេកឃើញកូស៊ីយ៉ា-ហុស្សាំងកាលណា. នាងក៏ស្គាល់ភ្លាមថា ជាមេចោរ ទោះបីជាវាស្លៀកពាក់ក្លែងក្លាយយ៉ាងណាក៏ដោយ ។ រួច ដោយនាងខំពិនិត្យយ៉ាងម៉ត់ចត់ទៅ នាងក៏បានឃើញថា វាមានកាំបិត ស្នៀតមួយលាក់នៅក្រោមអាវ ។ នាងក៏នឹកក្នុងចិត្តថា : "អញឥត ឆ្ងល់ឡើយថា អាជនកំណាចនេះ វាឥតចង់អាស្រ័យអំបិលជាមួយនឹង ចៅហ្វាយអញទេ ។ វាជាមហាសត្រូវរបស់ចៅហ្វាយអញ. វាចង់ សម្លាប់ចៅហ្វាយអញ. ប៉ុន្តែអញនឹងការពារកុំឱ្យវាសម្លាប់គាត់បាន" ។ កាលបើមរ្យ៉ានរៀបចំម្ហូបអាហារសព្វគ្រប់ហើយៗប្រាប់ឱ្យអាប់ដាល្លានៅបម្រើភ្ញៀវ. នាងក៏ឆ្លៀតយកពេលគេបរិភោគអាហារនេះ ទៅ

រៀបចំធ្វើកិច្ចប្រហារជីវិតដល់ភ្ញៀវក្លែងក្លាយនេះ ។ នាងទើបតែនឹងធ្វើការនោះហើយ អាប់ដាល្លាក៏ចូលទៅប្រាប់ថា ដល់ពេលលើកផ្លែឈើហើយ ។ នាងក៏លើកផ្លែឈើយកទៅដាក់លើតុ ក្រោយពីអាលី-បាបាលើកយកចានម្ហូបអាហារចេញ ។ តមកទៀត, នាងយកកូនតុមួយទៅដាក់ជិតអាលី-បាបា, រួចនាងយកដបស្រានឹងកូនពែងតូចបីដាក់លើនោះ។ នៅពេលថយចេញ នាងក៏ដឹកដៃអាប់ដាល្លាមកជាមួយហាក់ដូចជាបបួលគ្នាទៅអាស្រ័យបាយ, ហើយនឹងទុកឱកាសឱ្យអាលី-បាបាកំសាន្តលេងសប្បាយជាមួយនឹងភ្ញៀវតាមទម្លាប់ នឹងក្រេបនូវទឹកស្រវឹងតាមចិត្ត ។

នៅពេលនោះ, កូស៊ីយ៉ា-ហុស្សាំង ឬបើហៅឱ្យចំជាមេនៃចោរ ៤០ ស្មានថាជាឱកាសល្អដល់វាហើយ ដើម្បីនឹងចាក់កអាលី-បាបាសម្លាប់ ។ វាបានគិតក្នុងចិត្តវាថា : "អញនឹងបំផឹកជនទាំងពីរឪពុកនឹងកូននេះឱ្យស្រវឹង ឯកូនវាដែលអញត្រូវទុកជីវិត, ក៏ពុំអាចរារាំងអញកុំឱ្យរុញចុងកាំបិតទៅក្នុងបេះដូងឪពុកវាបានដែរ ។ រួចអញនឹងរត់គេចខ្លួនតាមសួនច្បារដូចជាអញបានរត់ពីពេលមុន, នៅពេលដែលអាឡាវិកា (ស្រីធ្វើបាយ) នឹងទាសាកំពុងដេកលេងនៅក្នុងផ្ទះបាយ" ។

មិនឯញ៉ាំបាយ, នាងមរ្សីយ៉ានដែលបានដឹងកិច្ចការនៃកូស៊ីយ៉ាក្លែងក្លាយ, ក៏ឥតបានទុកពេលឱ្យជននោះធ្វើអំពើអាក្រក់បានឡើយ ។ នាងតែងតួជាអ្នករាំយ៉ាងល្អឆើត, ពាក់មួកយ៉ាងសម ហើយក្រវាត់ខ្សែក្រវាត់ប្រាក់ជ្រលក់មាស ដែលនៅជាប់នឹងនោះ នាងបានសៀតកាំបិតស្នៀតមួយ ។ កាំបិតស្នៀតនោះទាំងស្រោមទាំងផ្លែធ្វើអំពីលោហធាតុតែមួយ ។ រួចនាងយកគ្រឿងប្រដាប់សម្រាប់ពាក់មុខយ៉ាងល្អមកពាក់កាលបើស្លៀកពាក់ដូច្នេះរួចហើយ នាងក៏ប្រាប់ទៅអាប់ដាល្លាថា : "អាប់ដាល្លា, ចូរឯងយកស្គរឡាំរបស់ឯងចេញមក, ហើយយើងនឹងចេញទៅរាំជូនភ្ញៀវរបស់ចៅហ្វាយយើង ដែលត្រូវជាមិត្តកូនប្រុសគាត់មើល, ដូចដែលយើងធ្លាប់បានលេងម្តងមួយកាលមក" ។ អាប់-ដាល្លាក៏យកស្គរឡាំកាន់ឡើង, យកដៃទះដើរមុខនាងមរ្សីយ៉ានហើយចូលទៅក្នុងបន្ទប់ ។ នាងមរ្សីយ៉ានកាលចូលទៅដល់ ក៏ឱនគោរពភ្ញៀវយ៉ាងទន់ភ្លន់ដោយទឹកមុខញញឹម ជាកិច្ចកលឱ្យភ្ញៀវងាកមើលខ្លួនហើយហាក់ដូចជាសុំអនុញ្ញាតឱ្យភ្ញៀវចាំមើលខ្លួនលេងតាមចំណេះ ។



អាប់ដាល្លា កាលបើឃើញ អាលី-បាបាចង់និយាយក៏ឈប់យកដៃទះស្គរ ។ អាលី-បាបានិយាយថា : "មរ្សីយ៉ាន, ចូលមក ! ចូលមក ! លោកកូស៊ីយ៉ា-ហុស្សាំងនឹងវិនិច្ឆ័យតាមការដែលនាងអាចធ្វើបាន ហើយស្រេចតែលោកយល់ឃើញដូចម្តេចក៏ដោយ" ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយលោក, គាត់បែរនិយាយទៅកាន់កូស៊ីយ៉ា-ហុស្សាំង សូមលោកកុំស្មានថា ខ្ញុំចំណាយអស់ប្រាក់កាសច្រើនណាស់ដើម្បីធ្វើឱ្យលោកសប្បាយនោះ ។ នៅផ្ទះខ្ញុំគឺដូច្នេះឯង, លោកឃើញស្រាប់ហើយថា គឺជាទាសីទាសានឹងអាឡាវិកាខ្ញុំទេតើ ដែលលេងនេះ ។ ខ្ញុំសង្ឃឹមថា លោកឥតមានទាស់ចិត្តឡើយ ។

កូស៊ីយ៉ា-ហុស្សាំងមិនបានជានឹកឃើញថា អាលី-បាបា មានធ្វើកិច្ចរាំលេងសប្បាយបន្ថែមលើពេលបាយនោះទៀតទេ ។ ការនេះធ្វើឱ្យវាបារម្ភក្រែងវារកឱកាសល្អពុំបាន ។ តែបើសិនជាដូច្នោះមែន, ក៏វាសង្ឃឹមថានឹងរកឱកាសឃើញដែរ ដោយបន្តមេត្រីភាពរបស់ខ្លួនជាមួយឪពុកនឹងកូនទៅថ្ងៃមុខទៀត ។ ដូច្នោះវាក៏សម្ដែងសេចក្ដីរីករាយទៅកាន់អាលី-បាបាថា ការណាក៏ដោយឱ្យតែធ្វើឱ្យលោកសប្បាយចិត្ត ខ្ញុំក៏នឹងសប្បាយផងដែរពុំខាន ។

អាប់ដាល្លា កាលបើឃើញភ្ញៀវនឹងចៅហ្វាយខ្លួនឈប់ជជែកគ្នាភ្លាម, វាក៏ចាប់ទះស្គរក្ដុងឡើងព្រមទាំងច្រៀងបន្ទរបទសម្រាប់រាំទៀតផង ។ នាងមរ្ស៊ីយ៉ានដែលធ្លាប់តែរាំពុំដែលចាញ់ស្រីដែលប្រកបរបររកស៊ីរាំម្ដងណាសោះ, ក៏រាំយ៉ាងល្អគួរឱ្យគយគន់ សូម្បីតែពួកអ្នករាំដូចគ្នាក៏សរសើរនាងដែរ ។ ដូច្នោះឥតបាច់សង្ស័យឡើយថា កូស៊ីយ៉ាហុស្សាំងក៏សរសើរនាងមិនតិចដែរ ។

ក្រោយដែលបានរាំបញ្ចេញក្បាច់ជាច្រើន, នាងក៏ហូតកាំបិតស្នៀតមកកាន់នឹងដៃ, ហើយចាប់រាំក្បាច់ម្យ៉ាងដែលមានធ្វើមុខមាត់ជាបែបផ្សេងៗ ដោយធ្វើចលនាកាយទន់ល្វតល្វៃ, លោតហក់បង្វិលខ្លួនតាមកម្លាំងគួរឱ្យស្ញើច, ជួនកាលនាងរាំដោយកាន់កាំបិតស្នៀតត្រង់ទៅមុខ ហាក់ដូចជាចង់យាវវាយអ្វី ជួនកាលធ្វើហាក់ដូចជាចង់យកកាំបិតមកវាយដោះនាង ។



នៅទីបំផុត នាងក៏យកដៃឆ្វេងកញ្ឆក់ស្គរឡាំពីដៃអាប់ដាល្លារីឯដៃស្ដាំនាងកាន់កាំបិត ។ នាងហុចស្គរពីខាងបាតចំពោះទៅមុខអាលី-បាបា ការនេះនាងធ្វើតាមពួកនាដកាទាំងឡាយ ដែលបានប្រើមធ្យោបាយនេះ ដើម្បីសុំលុយពីពួកទស្សនជនទាំងឡាយតាមសទ្ធាគេ ។

អាលី-បាបា ក៏ទម្លាក់ប្រាក់មាសមួយដុំទៅក្នុងស្គរនាងមរ្ស៊ីយ៉ាន, រួចនាងក៏ធ្វើកិច្ចដូចជាខាងលើនេះទៅកាន់កូន អាលី-បាបាទៀត ។ កូនអាលី-បាបាក៏ធ្វើតាមឪពុកខ្លួន ។ កូស៊ីយ៉ា-ហុស្សាំងដែលយល់ជាមុនថា នាងមុខជាមកកាន់ខ្លួនដែរក៏បានហូតថង់ប្រាក់ចេញពីក្នុងអាវស្រេច ដើម្បីជូនជារង្វាន់ដល់នាង ។ នៅពេលតំណាលគ្នានឹងគាត់លូកដៃយកលុយនោះ នាងមរ្ស៊ីយ៉ាន ប្រកបដោយសេចក្ដីក្លាហានយ៉ាងម៉ឺងម៉ាត់ នឹងសេចក្ដីក្ដៅចិត្តមកជាយូរហើយ, ក៏រុញកាំបិតទៅចំកណ្ដាលដើមទ្រូងមេចោរ, លុះត្រាតែមេចោរផុតជីវិត ទើបនាងដកកាំបិតចេញ ។

អាលី-បាបានិងកូន ភ័យស្រឡាំងកាំងនឹងឃាតកម្មដូច្នោះ, ក៏ស្រែកឆោឡោឡើងថា, "ឃីស្រីកាឡកិណ្ណី ឯងធ្វើអ្វីយ៉ាងនេះ តើដើម្បីឱ្យយើងនឹងគ្រួសារយើងស្លាប់វិនាសអស់ឬ?"

ទេ !, មិនមែនធ្វើដើម្បីឱ្យលោកស្លាប់ទេ គឺខ្ញុំធ្វើដើម្បីរក្សាជីវិតលោកឱ្យគង់នៅទេតើ?

នៅពេលនោះ ទាសីវៃឆ្លាតក៏លាត់អាវកូស៊ីយ៉ា-ហុស្សាំង ដើម្បីធ្វើឱ្យអាលី-បាបាឃើញកាំបិតស្នៀតដែលវាបង្កប់នៅនឹងខ្លួន ។ នាងពោលថា : "សូមអញ្ជើញលោកមើល, ជនជាសត្រូវដ៏ឆ្កើមរបស់លោកនេះជានរណា សូមលោកសម្លឹងមើលមុខវាឱ្យមែនទែនមើល លោកនឹងស្គាល់ថាជាឈ្មួញលក់ប្រេងក្លែងក្លាយ នឹងជាមេនៃចោរ៤០។ លោកមិនជ្រាបទេឬ អំពីការដែលវាមិនព្រមស៊ីអំបិលជាមួយនឹងលោក? មុនដែលខ្ញុំបានឃើញជននោះ ខ្ញុំមានសេចក្ដីសង្ស័យស្រេចទៅហើយ, នៅពេលដែលលោកបានប្រាប់ខ្ញុំថា មានភ្ញៀវយ៉ាងនេះមកអាស្រ័យបាយ ។ លុះខ្ញុំបានឃើញ, លោកក៏ឃើញច្បាស់ថា សេចក្ដីសង្ស័យរបស់ខ្ញុំឥតមានខុសបន្តិចឡើយ ។

អាលី-បាបា ក៏ដឹងថា ខ្លួនត្រូវជំពាក់គុណមរ្ជីយ៉ានជាថ្មីមួយទៀត ព្រោះនាងបានជួយយកអាសាខ្លួនជាលើកទីពីរ ទើបវាស្ទុះទៅឱបរឹតនាងដោយស្និទ្ធស្នាល ហើយពោលថា: "មរ្ជីយ៉ាន ! ខ្ញុំបានបើកសេរីភាពឱ្យឯងម្ដងទៅហើយ ថែមទាំងបានសន្យានឹងឯងថា សេចក្ដីតបគុណរបស់យើងមិនមែនអស់ហើយតែត្រឹមនេះទេ ហើយមិនយូរប៉ុន្មានខ្ញុំនឹងធ្វើឱ្យឯងពេញចិត្ត ។ ឥឡូវពេលវេលាមកដល់ហើយ, ខ្ញុំសូមដណ្ដឹងឯងធ្វើជាកូនប្រសាខ្ញុំ" រួចវាក៏និយាយទៅកាន់កូនប្រុសវាថា : "កូនប្រុសមាសសម្លាញ់ឪពុក, ឪពុកយល់ថាឥតមានត្រូវប្រកែកឡើយ ក្នុងការដែលឪពុកលើកនាងមរ្ជីយ៉ានឱ្យធ្វើជាប្រពន្ធឯង ដោយ



ឥតបានពិគ្រោះសួរឯងជាមុននេះ ។ កូនឯងក៏មិនមែនត្រូវមានឧបការគុណយ៉ាងតិចប៉ុន្មានដល់នាងដូចជាឪពុកដែរ កូនឯងឃើញហើយថា កូស៊ីយ៉ា-ហុស្សាំង បានរកផ្លូវចងមេត្រីភាពជាមួយនឹងកូនឯង ដើម្បីវាងាយនឹងសម្លាប់ឪពុកតាមអំពើក្បត់ពាលរបស់វា ហើយបើសិនជាបំណងល្អនេះបានសម្រេចមែន, កូនឯងឥតត្រូវសង្ស័យឡើយថា វាមុខជាធ្វើពលិកម្ម ដើម្បីតាមសងសឹកកូនឯងឱ្យបានទៀត ត្រូវកូនឯងគិតឱ្យវែងឆ្ងាយថា ការដែលកូនឯងរៀបការជាមួយនឹងនាងមរ្ជីយ៉ាននេះ ឈ្មោះថាកូនឯងបានរៀបការជាមួយនឹងជនជាទីពំនាក់អាស្រ័យម្នាក់នៃគ្រួសារឪពុក នៅពេលដែលឪពុករស់នៅ នឹងជាទីបង្អែកយ៉ាងមាំរបស់កូនឯង លុះត្រាដល់អវសានជីវិតរបស់កូនឯង" ។

យុវជនជាកូនឥតមានសម្ដែងអាការៈស្ទាក់ស្ទើរក្នុងចិត្តត្រង់កន្លែងណាបន្តិច ក៏ជម្រាបប្រាប់ឪពុកថា ខ្លួនសុខចិត្តរៀបការជាមួយនាង។ ការស្រុះស្រួលនេះ ដោយមិនមែនមកពីយុវជនខ្លាចក្រែងគេថាខ្លួនជាកូនមិនលុះដោយដំបូន្មានឪពុកម្ដាយទេ គឺមកពីខ្លួនយុវជនផ្ទាល់នេះឯង បានមានចិត្តទោរទន់ទៅលើនាងមរ្ជីយ៉ានស្រាប់មកផង ។

តពីនោះមក, គេក៏ចាប់គិតគូគ្នាយកខ្មោចអាមេចោរទៅកប់នៅកន្លែងជិតកន្លែងដែលបានកប់ចោរ៣៧ នាក់មុន ។ ហើយការនោះក៏បានហើយជាស្រេច ដោយសេចក្ដីស្ងប់ស្ងៀម, លុះកន្លងពេលជាយូរឆ្នាំក្រោយមក ទើបគេបានដឹងរឿងនេះពិតប្រាកដ, គឺគេបានដឹងនៅពេលដែលគេបានយករឿងនេះទៅបោះពុម្ពផ្សាយបាន ។

ចំនួនជាប៉ុន្មានថ្ងៃក្រោយបន្តិចមក, អាលី-បាបា ក៏តុបតែងរៀបចំការកូនប្រុសគាត់ជាមួយនឹងនាងមរ្ស៊ីយ៉ាន យ៉ាងអឹកធឹកជាទីបំផុត, មានធ្វើម្ហូបអាហារជប់លៀងយ៉ាងសម្បូណ៌ហូរហៀរ មានរាំ, មានមហោស្រព នឹងមានការកំសាន្តផ្សេងៗទៀតជាច្រើន ដែលគេធ្វើទៅតាមទម្លាប់ស្រុក ។ មួយចំណែកទៀតអាលី-បាបា មានសេចក្តីសប្បាយរីករាយជាក្រៃលែង ដោយបានឃើញសម្លាញ់នឹងញាតិមិត្តជិតខាងដែលខ្លួនបានអញ្ជើញមកជាភ្ញៀវក្នុងពិធីនេះ ហើយដែលឥតបានដឹងហេតុពិតប្រាកដ នៃការរៀបអាពាហ៍ពិពាហ៍នោះផង ប៉ុន្តែភ្ញៀវទាំងនោះ បានស្គាល់ច្បាស់នូវគុណសម្បត្តិដ៏ល្អប្រពៃរបស់នាងមរ្ស៊ីយ៉ាន បានពោលសរសើរគាត់ជាច្រើនចំពោះចិត្តបុណ្យនឹងចិត្តស្លូតត្រង់របស់គាត់ ។

លុះរៀបមង្គលការកូនរួច, អាលី-បាបា ដែលខានបានត្រឡប់ទៅកាន់រូងថ្មតាំងពីពេលដែលវាបានទៅយកសពបងវា នឹងមាសខ្លះមកនោះ ក៏ខានទៅកាន់រូងថ្មនោះទៀត តាំងពីពេលមរណភាពនៃចោរ ៣៨ នាក់នោះ, ដោយបារម្ភក្រែងពួកចោរនៅក្នុងនោះលបលួចព័ទ្ធចាប់វាបាន, ព្រោះវាបាននឹកស្មានថា ក្រែងចោរពីរនាក់ដែលបាត់ពីចំនួនចោរ៤០ នោះ មានជីវិតរស់រាននៅឡើយ ពុំដឹងជាមានវាសនាយ៉ាងម៉េច ។

ប៉ុន្តែ, លុះកន្លងមួយឆ្នាំមក, ដោយវាសង្កេតឃើញថា ពុំដែល



មានកើតហេតុអ្វីគួរឱ្យពិចពិលសោះ វាក៏កើតចិត្តចង់ធ្វើដំណើរទៅកាន់ទីនោះ ប៉ុន្តែដោយសេចក្តីប្រយ័ត្នប្រយែងជាទីបំផុត វាក៏ឡើងជិះសេះ ។ លុះទៅដល់ជិតរូងសិលា វាក៏យល់ថាជាប្រផ្នូលល្អ ដោយវាសង្កេតទៅឥតឃើញមានស្នាមជើងមនុស្ស ឬសេះត្រង់កន្លែងណាបន្តិចបន្តួចដើម្បីជាសញ្ញាឡើយ ។ ចុះពីខ្នងសេះភ្លាមយកសេះទៅចង, រួចដើរទៅមុខមាត់ទ្វារ វាក៏ពោលពាក្យដែលវាចាំឥតភ្លេចថា: “សេសាមចូរឯងបើក” ។ ទ្វារក៏របើកឡើង វាក៏ដើរចូល ។ សភាពនៃរបស់ទាំងឡាយនៅក្នុងរូងថ្ម ធ្វើឱ្យវាពិចារណាឃើញថា តាំងពីពេលដែលកូស៊ីយ៉ា-ហុស្សាំងទៅជួលហាងនៅឯទីក្រុង គ្មានមនុស្សម្នាណាម្នាក់បានចូលមកក្នុងរូងនេះឡើយ ដូច្នេះហ្វូងចោរ៤០ ប្រាកដជាស្លាប់អស់តាំងពីពេលនោះមកហើយ ។ វាក៏ឥតសង្ស័យទៀតឡើយថា ក្នុងលោកនេះមានតែវាម្នាក់ឯងទេ ដែលដឹងការអាថិកំបាំងដើម្បីបើកទ្វាររូង ដែលនៅក្នុងនោះ មានឃ្លាំងមាសឃ្លាំងប្រាក់ទុកជាកំណប់ជីវិតរបស់វា ។ នៅពេលនោះវាបានយកហឹបមួយជាប់ទៅនឹងខ្លួន, វាបានយកមាសប្រាក់ដាក់ឱ្យល្មមតាមកម្លាំងសេះវា, រួចវាក៏ត្រឡប់មកកាន់ទីក្រុងវិញ ។

ចាប់តាំងពីពេលនោះមក, អាលី-បាបា ក៏នាំកូនទៅកាន់កន្លែងចោរនោះ ហើយបាននិយាយប្រាប់កូនវាអំពីការណ៍អាថិកំបាំង ដើម្បីចូលទៅក្នុងរូង ។ អាស្រ័យហេតុដូច្នេះ, ជនទាំងពីរនាក់ ឪពុកនឹងកូន

ក៏បានរស់នៅដោយសេចក្តីថ្កុំថ្កើងរុងរឿង និងបានទទួលកិត្តិយសជាអ្នកថ្លៃថ្នូរបំផុតក្នុងរាជធានី ។

លុះបាននិយាយរឿងនោះថ្វាយព្រះបាទស៊ុលតង់ចប់, នាងសេហេរ៉ាសាដ ដោយបានសង្កេតឃើញនៅយប់ពុំទាន់ភ្លឺនៅឡើយ, ក៏ចាប់និយាយថ្វាយព្រះអង្គនូវរឿងមួយទៀត ដែលមានសេចក្តីដូចតទៅនេះ ។

(ចប់រឿង អាលី-បាបា តែប៉ុណ្ណោះ) ។